# សុត្តុនទេវ

B-10
D-80
N°371

ភាគ១



ប័យជាតិ
80

# រឿងសុគុណាបោង

ខ្សែ ១

រៀបរៀងសម្រួលតាមច្បាប់ដើម

ដោយ - សុជីវិត

ការផ្សាយរបស់

លេខ ១៩ វិថីព្រះបាទត្រសក់ផ្អែម ខាងត្បូងផ្សារធំថ្មី ក្រុងភ្នំពេញ

រក្សាសិទ្ធិ

ព. ស. ២៤៩៩ - គ. ស. ១៩៥៦

DÉPÔT LÉGAL
B. 114. 1357

# រឿងសុគុណហោង

និទាននេះមាន ព្រះមហាក្សត្រក្សាន្ត ឯកពង្សមួយណា ស្ដេចសោយសម្បត្តិ គ្រងរាជវង្ស នគរហៅមហា ក្រុងការបុរី ៗ នាមឈ្មោះព្រះបាទ សាមលនរនាថ ទេពីនាមនៃ នាងចន្ទវេក្ខា ល្អណាស់ពេកក្រៃ ស្ដេចសព្វព្រះទ័យ លើកនាងជាច្បង ៗ ជាធំលើសស្រី ប្រាំបីម៉ឺននៃ បម្រើនាងហោង យុទណាងស្រីស្នំ ច្រើនក្រៃកន្លង ពុំដែលខុសឆ្គង ទឹងនាងឡើយណា ៗ មានប្រាង្គប្រាសាទ ប្រសើរស្អាងស្អាត ក្បូរក្បាច់រចនា បិតមាសភ្លឺទេង ជាំត្បូងមុក្តា ភ្លឺផ្លេកអស្ចារ្យ សប្បាយពេកក្រៃ ៗ ស្ដេចមានអំណាច ប្រសើរអង់អាច លើសគេដទៃ មានវត្ថុចំណុះ មួយរយម្ដៃ នាំអស់សួយរៃ ថ្វាយព្រះរាជា ៗ បំណោរលន់ទៅ សុខសាន្តនិត្យនៅ ស្ដេចមានបុត្រា មួយល្អបរិសុទ្ធ ស្រឡាញ់ណាស់ណា សន្មតនាមថា ព្រះបាទព្រហ្មទត្ត ៗ លុះចំរើនវ័យ ដប់ប្រាំហើយនៃ សក្តិសមធំធាត់ ចង់ចេញលេងព្រៃ យាងត្រាច់

វង្កត់ តាមដោយជនបទ គិរីបព្វតា ។ ហើយទ្រង់យាងទៅ ទីបានលំនៅ ប្រាសាទបិតា លើកករប្រណម្យ ទូនអង្គ សេរិសា កូនទឹងសុំលា ទៅលេងស្រះស្រង់ ។ សម្តេច បិតា ទ្រង់មានមេត្តា បើកតាមបំណង ព្រះរាជបុត្រា មានព្រះទ័យចង់ ក្រសាលស្រះស្រង់ បើកតាមចិន្តា ។ ព្រះបាទព្រហ្មទត្ត លាព្រះមហាក្សត្រ សម្តេចបិតា ស្រេច ហើយបង្គាប់ អស់ពួកសេនា រៀបពលយោធា ដង្ហែទៅ ហោង ។ ស្រាប់ស្រេចម្មីមា ចេញចរលីលា តាមហែ ត្រសង យាត្រាស្តេចចេញទៅ ក្រៅបន្ទាយហោង ដល់ព្រៃ ជាម្តង គិរីបព្វតា ។

(បទភុជង្គ) ប្រែបទលេងព្រៃវិញណា

ព្រះបាទក្សត្រា ទតអស់ផ្កាផង ។ អង្គាបុស្សបុប្ផានោះហោង ផ្កាស្លឹកផង រុះរោយដោយដី ។ ព្រះបាទនរនាថចក្រី ទតផ្កាចំប៉ី ចម្ប៉ាមហាហង្ស ។ សេនាយោធាពុំលង់ បេះថ្វាយ នោមយង់ អស់ផ្កាទាំងឡាយ ។ ឈើផងលូតលាស់ខ្ពស់ឆ្ងាយ

ព្រីងព្រះខុរស្វាយ គគ៏ផ្ចឹកកាំង ៗ តាត្រាវឈើខ្មៅព្រួសក្តាំង
ស្តុកស្តោស្តីទាំង កោកាវនីការ ៗ ស្តេចទតអស់សត្វ
បក្សា បក្សីធងណា ច្រើនក្រៃកន្ទួង ៗ ទតយល់នូវសត្វ
កេងកង ទំដើមសំរោង ជ្រួកជ្រកក្រោមនៃ ៗ ក្ងោក
ទំលើដើមជ្រៃ គ្រប់ព្រៃនៃ ជ្រកក្រោមម្លប់ណា ៗ ស្តេចទត
ឃើញសត្វសារិកា ទំលើដើមតាស្កា នៅក្រោមហោង ៗ
ស្តេចទតឃើញសត្វត្រយង មានឈ្មោលញីផង បបិកគ្នា
គួរ ៗ សត្វទុងហើរទំដើមត្នៅ ដំរីឈរនៅ ក្រោមម្លប់
នោះណា ៗ ស្តេចទតឃើញសត្វក្រសា ទំដើមពុទ្រា
ស្រែកយំអឺងកង ៗ កាលនោះក្សត្រក្សត្ដបព្វាស់ព្យង ទត
អស់សត្វផង ក្រសាលសប្បាយ ៗ សេនាយោធាទាំងឡាយ
ហែក្សត្រតាមឆាយ ទៅដល់ស្រះស្រង់ ៗ សេនាពុំមានបង្អង់
បបួលគ្នាសង់ ព្រះពន្លាជៃ ៗ ស្រេចហើយទូលព្រះចក្រី
ក្សត្រាធិបតី គង់សម្រាកកាយ ៗ សេនាលែងសេះប្រញាយ
ដំរីទាំងឡាយ ឲ្យទៅស៊ីស្មៅ ៗ ពាហនៈរួតរត់ទៅពៅ ទៅរក

ស៊ីស្មៅ ឃើញកូនអស្សពាហ៍ ។ សសុទ្ធដូចផ្កាចម្ប៉ា សត្វផងនានា ដើរចូលជិតទៅ ។ គិតស្មានថាមេវានៅ នាំគ្នាចូលទៅ កូនសេះនោះណា ។ ដល់ហើយដណ្ដឹងសួរថា អ្នកមកពីណា ប្រាប់ឲ្យដឹងផង ។ កូនសេះមិនខ្វីឆ្លើយឆ្លង ដើរចេញជាម្ដង ពីគេនោះនៃ ។ ពុំមានទឹកខ្លាចភិតភ័យ ហេតុពូជប្រពៃ ជាស្ដេចអស្សពាហ៍ ។ កាលនោះឯអស់យោធា ឃើញកូនអស្ស-ពាហ៍ ត្រេកអរពេកក្រៃ ។ រត់ទៅក្រាបទូលក្សត្រថ្លៃ ឲ្យជ្រាបសេចក្ដី ពីរឿងអស្សពាហ៍ ។ ស្ដេចទ្រង់បង្គាប់យោធា នាំព្រះពាជា ទៅមើលសេះហោង ។ សម្បុរសល្អកន្ទង់ លើសលែងសេះផង អញពុំដែលយល់ ។ ជើងបួនសមសួនគ្មានទាល់ គ្រប់កល្អសល់ ដូចកែវមុក្ដា ។ ស្ដេចទតមើលភ្នែកសេះណា ខ្មៅដូចកូមក៉ា ភ្លឺផ្លេកយល់យង់ ។ គន់រូបគន់ទ្រាយទ្រើសទ្រង់ រូបល្អសក្ដិសម ពេកពន់ណាស់នៃ ។ ទើបអង្គក្សត្រាធិបតី ដណ្ដឹងសួរខ្មី ទៅកូនអស្វ ។ បាមកពីទីឋានណា មកនៅឯកា ឥតគូកនឡើយ ។ មេបាទៅឯណាហើយ

ម្ដេចមិនឃើញឡើយ ប្រាប់មកយើងរ៉ា ។ កាលនោះឯកូន
អស្សា ស្ដាប់ព្រះឱង្ការ ទៀងទូលទៅវិញ ។ បពិត្រខ្លួនខ្ញុំនេះនៃ
ពុំដឹងជាបិ-តាមាតាឡើយ ។ ខ្ញុំឮសារិកាចាស់ឆ្លើយ ប្រាយ
ប្រាប់ខ្ញុំហើយ ថាមេនោះណា ។ គាត់នៅឧត្តរទិសា នាំគ្នា
យាត្រា មកលេងស្រះស្រង់ ។ ពេលនោះមេខ្ញុំផើមផង ខ្លួន
ខ្ញុំនេះហោង កើតទីនេះនៃ ។ កើតរួចគាត់ថាខ្ញុំក្ស័យ ចោល
ខ្ញុំនេះវិញ ហោះទៅបាត់ហោង ។ ស្ដេចយកព្រះហស្ដប៉ាស
ខ្នង ហើយត្រាស់សាសង ទៅនឹងអស្សពាហ៍ ។ យើង
ឃើញឯងនេះកំព្រា អញនឹងឃានា យកទៅគេហ ។ កុំនៅ
ទីនេះឡើយណា អញនឹងយកបា ចិញ្ចឹមជាម្ដង ។ ហើយ
ទើបក្សត្រថ្ងៃសាសង ឲ្យអស់ពលផង គេហអស្សពាហ៍ ។
ហើយស្ដេចចុះស្រង់គង្គា ស្រះស្រីរងថ្វា បេះអស់ផ្កាផង ។
ព្រះកាយផាត់ផាយមកត្រង់ ដូចគេអប់អង្គ ពិដោរជាប់នៅ ។
ព្រះមហាក្សត្រាទតទៅ យល់ឈូកប្រាលផ្អៅ លំបង់ស្បង្កិដ ។
ត្រកួនកព្ទាតល្អផ្កាច់ សារាយល្ងតលេច ពីទឹកនោះហោង ។

ពួកពលសប្បាយអឹងកង បាចទឹកសាសង ទៅវិញទៅមក ។ ស្តេចទ្រង់ទតឃើញត្រីឆ្កោក ត្រីប្រួលហែលមក ចិកយកត្រីពល ។ ព្រលូងគល់ពំងកដា មានត្រីចង្វា ផ្ទោងផ្ទក់ក្រញ្ជួក ។ ក្រហែត្រីពោគគោក ត្រីខ្ជឹងរែងស្តុក ត្រីរ៉ស់សណ្តាយ ។ ព្រះបាទនរោទឆោមឆាយ រីករាយសប្បាយ ក្នុងព្រះហឫទ័យ ។ ក្រសាលស្រះស្រួបហើយនៃ ហៅពួកសេនីយ ត្រឡប់ចូលវាំង ។ ក្រាបទូលបិតាព្រមទាំង មាតាបន្ទូចាំង វេក្ខាក្យត្រៃថ្ងៃ ។ ខ្ញុំបានសើសកូនអាជានេយ្យ កណ្តួស-រាជវៃថ្ង ពាំព្រៃស្រះស្រង់ ។ មកថ្វាយសម្តេចពីរអង្គ តើមានចំណង់ សត្វរាជហឫទ័យ ។ សម្តេចបិតាអរក្រៃ ថាសេះនេះនៃ ល្អក្រៃណាស់ណា ។ ទឹងយកអាជានេយ្យនានា មកប្រៀបផ្ទឹមគ្នា ពុំបានឡើយនៃ ។ ដ្បិតសេះកណ្តួសរាជនៃ យកវត្ថុអ្វី ថ្លៃពុំស្មើឡើយ ។ មានតែនគរជាត្រើយ ថ្លៃស្មើគ្នាហើយ គ្មានខុសឡើយនៃ ។ ឲ្យពលសង់រោងឆាប់រ៉ី ខ្ពស់ស្រួចលលៃ ធ្វើជាមណ្ឌប ។ ប្រក់ប្រាក់ថ្វាក់ក្បាច់សុះសត្វ

កំពូលមណ្ឌប ជាំត្បូងព្រោងព្រាយ ។ ប្រដាប់ពានមាស ពណ្ណរាយ ជម្ពល់ស្មៅលាយ សម្រាប់សេះហោង ។ ទ្រង់ចាត់សេនាចផង ឲ្យថែទាំហោង ជានិច្ចរាល់ថ្ងៃ ។ សឹងសុខសប្បាយពេកក្រៃ ឥតទុក្ខភ័យអ្វី នាំឲ្យកង្វល់ ។ និទានទុកស្មេះតម្កល់ ស្រូតរូតទៅដល់ តាបសឥសី ។

បទព្រហ្មគីតិកាល អំពីអង្គព្រះមហា មុនីរត្នឥសីលា គង់ស្ងំតនៅព្រៃហេមពាន្ត ។ ព្រៃភ្នំជាអាស្រមទីបង្ក្រមនោះសោតមាន ស្ទឹងស្មាធបម្រើនឈាន ព្រហ្ម-វិហារជាប្រក្រតី ។ និមន្តបរយោត្រា រកផលាធាន់សព្វថ្ងៃ វៀនវៀបជាប្រក្រតី សព្វទិវាពុំលោះឡើយ ។ មានកាលនាមួយថ្ងៃ ឥសីថ្ងៃចង់លំហើយ ចូលឈានពុំលង់ឡើយពោះដល់ស្រះបោក្ខរណី ។ ឯកុងស្រះនោះណា មានសុទ្ធផ្កាកែថ្មី ៗ ឧប្បលចង្កុលណី ក្បួរបេត្តក្រអូបសាយ ។ ឯលើឆ្នេរស្រះនោះ ឈើធំដុះវែងខ្ពស់ឆ្ងាយ មានដើមផ្កុលខ្ពស់ស្រោយ លូតស្រោងស្រោងម្លប់ត្រជាក់ ។ ឯតាបសឥសី គង់

មើលព្រៃបន់សំណាក់ ចរចូលទៅដល់ផាក់ គន់ក្រោមម្លប់ផ្កុល មាសនៃ ៗ ផ្កុលមាសនោះណា មានកញ្ញាសួគ៌ាល័យ បុត្រ ចុះមកនៃ ឧប្បត្តិកក្នុងផ្កាហោង ៗ ហើយស្រែកយំខ្លាំងសល់ ឮទៅដល់ឥសីហោង ឥសីដឹងជាម្តង ថាជាមនុស្សកើតក្នុងផ្កាៗ ខំស្ទុះទៅជិតមើល ឃើញកូនស្រីល្អអស្ចារ្យ នេះសមព្រេង វាសនា ជួយសង្គ្រោះជីវិតអញ ៗ ឥឡូវជាតិនេះណា ឃើញ កុមារសែនស្រឡាញ់ ដូច្នេះត្រូវតែអញ ជួយសង្គ្រោះឲ្យរស់ ហោង ៗ គិតស្រេចព្រះឥសី លើកឡើងបីហើយហោះផ្សង វិលថ្កនអាស្រមហោង ដល់ស្រេចហើយឥសីលា ៗ ថ្នាក់ ថ្នមមិនឲ្យហ្មង ប៉នសង្គ្រោះដោយមេត្តា ជបម្រាមព្រះហត្ថា ឲ្យបៀមបៅរាល់ថ្ងៃទៅ ៗ លុះដល់កុមារី ធំដឹងក្តីការពក់ ជ្រៅ ចេះស្តីសព្វហើយក៏ ត្រូវរដូវផ្កាផ្កុលធ្លាក់ ៗ រោយជ្រុះ កើតជាមាស ល្អពេញពាសទឹកដប់ផាក់ ឥសីអាតេតអាក់ ទ្រង់ស្មោះស្ម័គ្រពេកណាស់ណា ៗ ឥសីសន្មតឈ្មោះ តាម ហេតុនោះឲ្យនាមថា: សុគុណបោងកញ្ញា ដោយហេតុផ្កាផ្កុល

មាសហោង ៗ ឥសីក៏ជបគ្រឿង ល្អរុងរឿងពេកកន្លង
ប្រដាប់ស្អិតស្អាងផង ឲ្យដល់នាងជាច្រើនក្រៃ ៗ បំណោរ
លង់យូរថ្ងៃ តែងប្រណីអាចិន្ត្រៃយ ពុំដែលចោលឡើយនៃ
ថ្ងៃយប់ក្តីជានិច្ចហោង ៗ បើឥសីទៅរក ផ្លែឈើយកនាង
ទៅផង ពុំដែលចោលឡើយហោង ក្រែងចៅខ្លាចនៅម្នាក់
ឯង ៗ លុះបានជប់ប្រាំឆ្នាំ តាមបំណាំម្តាយបាត់បែង រូប
នាងល្អយ៉ាងខែង ទឹងប្រៀបផ្ទឹមពុំបានណា ៗ ទ្រង់
ទ្រាយឆើតឆោមសល់ ប្រសើរដល់លើសទេវតា ស្រ្តីក្នុង
កម្ពុជា នេះទឹងផ្ទឹមពុំបានឡើយ ៗ សូម្បីសាស្ត្រអ៊ឺរុប
ស្បែកសសព្វយ៉ាងណាដោយ ចិនយួនសៀមលាវហើយ
នៅតែផ្ទឹមចាញ់ជាម្តង ៗ ថ្ងៃមួយព្រះឥសី ចូលទៅ
ព្រៃបេះផលផង ដល់ថ្ងៃល្ងាចហើយហោង ត្រឡប់វិល
មកវិញណា ៗ ឯនាងសុគុណាថោង នាងនិត្យនៅ
ចាំសាលា ប្រុងប្រៀបសព្វកិច្ចការ ទុកប្រគេនឥសីហោង ៗ
លុះឃើញឥសីមក រត់ជជ្រកទទួលហោង អង្រែមកផ្លែឈើផង

យកទៅទុកដាក់ខ្លួនឯង ៗ ព្រឹកព្រាងស្រេចកាលណា នាងកញ្ញាផ្គាប់តាក់តែង លៃលកដោយដៃឯង ទៅប្រគេនតាឥសី ៗ សេសសល់ផ្លែនានា ពីតាយកមកញុំាខ្លី ពុំដែលញុំាមុនឡៃ សព្វវេលារៀងរបទៅ ៗ

( បទកាកគតិ ) ដំណើរដំណាល . ពីអគ្គក្សត្រា ព្រហ្មទត្តបព្រាស់ប្បង តាំងតែពីបាន កណ្តូសកដហោង ល្អក្រៃកកន្ទង កម្លាំងខ្លាំងសល់ ៗ ស្តេចឲ្យតែងគ្រឿង យ៉ាងល្អរុងរឿង សំអាតអស់កល់ បង្ហៀរឃុំមុខ ស្រោបមាសល្អសល់ អានកែបឈ្នាន់កល់ ទ្រព្រះបាទា ៗ អានគង់ផែមាស ដាំត្បូងឧកាស ក្លឹផ្ទុកអស្ចារ្យ ប៉ាក់ដោយសែសយ រំលេចរចនា ជាទីស្នេហា ស្រឡាញ់ពេកក្រៃ ។ ស្តេចក្មួករលឹក ស្រះស្រង់ពន្លឹក ដែលនៅក្នុងព្រៃ ចូលទូលបិតា ក្សត្រាធិបតី លាទៅលេងព្រៃ ស្រះស្រង់នោះណា ៗ កាលនោះព្រះបាទ សាមណនរនាថ ស្តាប់រាជបុត្រា ទូលដំណើរប្រាប់ ចង់ចេញយាត្រា លេងស្រះរងថ្កា ឯព្រៃហេមពាន្ត ៗ

ស្ដេចជ្រាបហើយនៃ ទ្រង់មានព្រះទ័យ អនុញ្ញាតបើកក្វាម ឲ្យពុំហ៊ានឃាត់ ដំណើរស្រុកហ្វូន ឲ្យទឹងប្រទាន តាម បិត្តបិត្តា ។ ព្រះបាទព្រហ្មទត្ត យល់ព្រះមហាក្សត្រ សម្ដេច បិតា ទ្រង់មានព្រះទ័យ ប្រណីករុណា បើកឲ្យយាត្រា បន្តិលាហោង ។ ចូលដល់ប្រាង្គប្រា សោមនស្សអស្ចារ្យ ត្រូវបំណុចចង់ ដល់ប្រាសាទហើយ បែរព្រះភក្ត្រទ្រង់ សំ-ដៅតម្រង់ មន្ត្រីសេនា ។ ទ្រង់ផ្ដាំឲ្យនៅ ដ្បិតខ្ញុំចេញទៅ លេងព្រៃព្រឹក្សា ខ្ញុំទៅនេះយូរ កុំគិតឡើយណា ទៅនឹងអស្សា ឥឡូវនេះហោង ។ ផ្ដាំស្រេចពុំលង់ ឲ្យប្រដាប់ទ្រង់ កណ្ឋស-ភជហោង ស្អិតស្អាងដោយគ្រឿង រុងរឿងកន្ទង់ ហើយ ឡើងគង់ហោង លើខ្នងអស្សពាហ៍ ។ រួចស្រេចហើយហោង អាជានេយ្យហោះផ្សង ឡើងលើវេហាស៍ ទក្សិណាបីជុំ នៃ ក្រុងភារា ហើយហោះទៅនា ឯព្រៃហេមពាន្ត ។ ហោះដល់ មាត់ស្រះ ក្សត្រថ្ងៃទតច្បាស់ ឲ្យអស្សាយាន បញ្ឈប់ជើង ចុះ ម្ជីម្ជាឈរឈាន ឯអស្សាយាន នាំស្ដេចចូលទៅ ។

ផ្រកម្ទប់ដើមផ្ទៃ អគ្គក្សត្រធិបតី គង់សម្រាកកូវ ទៀបក្បែរ
មាត់ស្រះ ទ្រង់ក្រឡេកទៅ ឃើញស្រីឆោមឆ្មៅ ដងទឹក
ស្រះណា ៗ ទើបស្ដេចលាក់ខ្លួន អស្សពោហ៍បំពួន បំបាំង
អាត្មា ដោយឃើញនាងដង ទឹកស្រះរេងថ្វា ឲ្យមហាក្សត្រា
លបមើលនាងហោង ៗ ក្នុងថ្ងៃនោះនៃ ជួនជាឥសី បំរើន
ធមិផង ពុំទៅណាឡើយ នៅអាស្រមហោង ការនាហ្មត់ហ្មង
ស្ងប់ស្ងាត់ពេកក្រៃ ៗ ស្រីស្រស់សោភា នាងចរលើលា
ញែងញ៉ីងល្ងន់ល្ងៃ ចរិយាសម្បត្តិ បុកពាល្អក្រៃ ដងទឹក
ហើយនៃ វិលទៅវិញណា ៗ នាងពុំដឹងខ្លួន ជាស្ដេចពឹង
ពួន ជាមួយអស្សា នៅនាឆ្នេរស្រះ ប៉ុនប៉ងប្រាថ្នា ចង់
បាននាងណា លាក់ខ្លួនគយគន់ ៗ ឯក្សត្របា.ប់ប្បង ទត
យល់នាងហោង រូបរាងល្អតល្អន់ សព្វព្រះហឫទ័យ ពេក
ក្រៃណាស់លន់ មិនឆ្អែតគយគន់ ក្នុងព្រះបន្ទា ៗ គន់សព្វ
សារពាង្គ រូបរាងនៃនាង គ្មានសល់ត្រង់ណា ស្ដេចគន់
ព្រះភក្ត្រ សមនឹងកាមា គន់ព្រះនាសា ស្រៀវស្រួចឡើងវែងៗ

វង់កក្រួត្រយង់ ឡើងមូលក្រឡង់ បីដូចវង់ខែ ចង្កេះរាងរៀវ សមនឹងស្នាដែរ សែនល្អម៉្លេះទេ ជាឆ្នើមលើសស្រី ៗ ទ្រង់ទ្រាយរូបា មានលក្ខណា ដើតដោមណាស់នៃ បើនឹងរិះរក យកស្រីដទៃ មកប្រៀបផ្ទឹមនៃ នឹងនាងគ្មានឡើយ ៗ នាងដើរទៅដល់ អាស្រមមណ្ឌល ព្រះឥសីហើយ យកទឹកទៅចាក់ ក្នុងអាងជាត្រើយ ប្រគេនតាហើយ អង្គុយនៅនៃ ៗ រីឯព្រះបាទ ព្រហ្មទត្តនរាធ កណ្ដួសរាជដៃ យល់នាងត្រឡប់ វិលទៅហើយនៃ ស្ដេចនឹងមនោម័យ យាងចូលតាមទៅ ៗ លុះដល់អាស្រម មុនីឧត្ដម ជួនចេញមកនៅ ក្រៅអាស្រមហើយ ទើបស្ដេចចូលទៅ បង្គំសៀមនៅ ក្ពោះកក្រួតសី ៗ មុនីសីលា ទតយល់ក្សត្រា ថ្វាយបង្គំខ្ចី មានថេរដីកា សាកសួរសេចក្ដី បុះចៅនេះនៃ មកពីឋានណា ៗ ចូលចៅប្រាយប្រាប់ អស់ការស្រាសព្ទ ដល់តាផងណា ប្រាប់នាមនៃលោក មាតាបិតា ស្រុកទេសឯណា នាមាឈ្មោះអ្វី? ៗ ម្យ៉ាង

ទៀតរូបទៅ ត្រាប់តាត់សំដៅ មកដល់តាខ្វី ក្នុងចិត្តព្រាហ្ម
មានបើកគម្ពី បូរទៅស្រដី ព្រាយប្រាប់តាហោង ៗ
ក្បៀណនោះព្រះបាទ ព្រហ្មទត្តនរនាថ ស្តាប់ព្រះសាសង
ពិតពុទ្ធដីកា ទូលតាវិញហោង ពីស្រុកទេសផង សព្វគ្រប់
ប្រការ ៗ ខ្ញុំករុណាម្ចាស់ សង្វាតវៃស្វែងស្វះ មកនេះព្រាហ្ម
ថ្វាយខ្លួនផងទៅ ជាសិស្សគណោណា សូមទ្រង់មេត្តា សង្គ្រោះ
ខ្ញុំហោង ៗ មុនីឥសី ស្តាប់ព្រះនរបតី ក្រាបទូលសាសង
ឥសីឈ្វេងយល់ ស្គាល់ចិត្តហើយហោង ស្តេចព្រាហ្មប៉ង
សុគុណថោងក្បូរ ៗ ឥសីអរក្តាត់ គន់គិតក្នុងចិត្ត មិនបង់
ទុកនៅ ដោយលោកព្រាហ្ម ស្និងស្នាធ័រកផ្លូវ ធ្វើឈាន
សំដៅ ឧត្តមដ្ឋាន ៗ សព្វថ្ងៃនេះនៃ តែងព្រួយព្រះទ័យ
ទៅឆ្ងាយពុំបាន ព្រោះទឹកអាណិត ស្រីរត្នកល្យាណ
ហេតុនោះលោកខាន ពុំបានទៅឡើយ ៗ ទ្រង់ជ្រាបថាក្សត្រ
ចូលមកប្រណិប័តន៍ បង់បាននានៈហើយ ទើបព្រះមុនី
ឥសីថ្លះថ្លើយ អាត្មាអរហើយ នឹងទៅណាសំណា ៗ

អាត្មាបានស្រី ដោយកើតពីសី នាងកើតក្នុងផ្កា អាត្មាបាន ឃើញ យកមករក្សា ឲ្យឈ្មោះហៅថា សុគុណថោង ហោង ។ អាត្មាគិតថា នឿយព្រួយរក្សា ពេកពនកន្ទង ឃើញ ស្តេចយាងមក ប្រគល់នាងហោង ផ្សំផ្គុំជាម្តង កុំព្រួយបិន្តា ។ ព្រះបាទព្រហ្មទត្ត ឮព្រះមុនីរត្ន មានបវរដីកា ថានឹងផ្សំផ្គុំ អវត្តៈឧបមា នឹងនាងកញ្ញា គាល់ព្រះឥសី ។ នាងនាដគយ គន់ មហាក្សត្រមានបុណ្យ រូបល្អប្រិមប្រិយ៍ ជាទីស្នេហា នៃនាងពេកក្រៃ ប្រុសក្នុងផែនដី រកផ្ទឹមពុំបាន ។ ឯព្រះឥសី ប្រើព្រះចក្រី បួលក្នុងសំសាន្ត ឲ្យរកបេះផ្កា ផ្សំផ្គុំកល្យាណ សុគុណថោងបាន ស្វាមីករិយា ។ កាលនោះព្រះបាទ ព្រហ្មទត្តនរនាថ ថ្វាយបង្គំលា ចុះចាកអាស្រម សំដៅទៅ នា ក្នុងដងព្រៃល្វា រកបេះផ្កាហោង ។ ស្តេចបេះនួនស្រី ម្ទះវត្តល្អក្រៃ ត្រឡប់វិញស្ងួន គន់គិតវេក នឹងគូស្នេហ៍ស្ងួន បួលទូលដោយដង ថាបានហើយនៃ ។ ចំណែកឥសី ទទួល ផ្កាខ្ចី អរក្រៃកន្លង ហើយអញ្ជើញស្តេច ក្រោមស្វេតឆត្រ

ធន់ សោយរាជ្យហ្មត់ហ្មង់ ប្រសើរហើយហោង ផ្ដុំផ្គុំ
ជាគ្នា ៗ ឯរង្គមហាក្សត្រ ក្រញក្រាបប្រណិប័តន៍ ឥសីលីលា
ទើបព្រះឥសី មានថេរដីកា ហៅទៅធីតា សុគុណាថោង
នៃ ៗ កាលនោះនាងនាជ កបបុកមារយាទ ឮព្រះឥសី
បន្ទូលហៅនាង ឲ្យគាល់បក្រី ត្រូវជាស្វាមី របស់នាងណា ៗ
នាងសែនអៀនខ្មាស ទុញទាល់ខ្លាំងណាស់ តែខ្លាចលោកតា
ចេញមកតាំងគាល់ បង្គំក្សត្រា ទឹងឥសីលា អង្គុយស្ងៀម
ហើយ ៗ ទើបព្រះឥសី ប្រាប់ទៅនាងខ្មី ថានៃចៅអើយ
ដៀតព្រះមហាក្សត្រ ព្រហ្មទត្តត្រាណត្រើយ មកសុំនាងហើយ
ធ្វើជាពន្ទិតា ៗ ឥឡូវតាឲ្យ នាងទៅស្ដេចហើយ អត់ទោស
ឲ្យតា បួលនាងទទួល ធ្វើជាកស្ដា កុំបីនាងថា ប្រកែក
អ្វីឡើយ ៗ ទោះបីលោកតា សង្គ្រោះករុណា ឲ្យខ្ញុំមានប្ដី
កុំថាស្ដេចឡើយ ដែលគ្រងបុរី ទោះសត្វអ្វីៗ ពុំប្រកែកទេ ៗ
ឯតាបស មានធម៌សប្បុរស ឮនាងមាសមេ លោកពុំបង្អង់
ឲ្យយូរឡើយទេ ទើបគិតកាញ់គ្នេរ រើសរកយកផ្កា ៗ

ឧប្បលទួនស្រី បាចលើកត្រៃថ្ម ប្រសិទ្ធពរថា ឲ្យមិត្រឲ្យ
មូល ដួបបួលចិន្តា រួមរក្ខាវសនា កុំបីមានហ្មង ៗ ឲ្យបាន
សោយពង្ស ទ្រង់រិទ្ធិអំណាច លើសអស់ស្ដេចធំ ឲ្យមាន
បុត្រា ចេស្ដាកន្លង បានសោយពង្សស្នង តំណាងបិតា ៗ
រីឯព្រះបាទ ព្រហ្មទត្តនរនាថ នឹងនាងជីតា ទទួលព្រះពរ
ទាំងពីរនាក់ណា អរឥតឧបមា ឥតអ្វីផ្ទឹមឡើយ ៗ ស្ដេច
នាំជាយា សុគុណថោងផា ទេពត្រាណត្រើយ ចូលក្នុងសាលា
ទាំងពីរអង្គហើយ ផ្ដុំរួមខ្នល់ខ្នើយ មូលមួយចិន្តា ៗ រួមរក្ស
សពាង្គ នៃបន្ទិត្យនឹងនាង ផ្ដេកផ្ដិតកាយា រួមរក្សមនោរម្យ
ផ្សំកេលេសា កម្លាំងតណ្ហា កិច្ចការកាមគុណ ៗ ហេតុតែ
សំណាង សំណូមសូមសាង មកពីជាតិមុន អំណាចផលទាន
សីលធម៌ផាទុន វិបាកផាបុណ្យ ជូនមកជួបគ្នា ៗ ស្ដេចបី
ត្រកង លើកនាងថ្នាក់ថ្នម ដាក់ឡើងលើនា ឧរូហើយនៃ
ព្រះទ័យរីងផា សោមនស្សរកគ្នា ទ្រង់ចេតចោមចាយ ៗ
អូនអើយអូនល្អ ក្នុងដែនដីក្រ រកស្រីទាំងឡាយ មកនឹង

ប្រៀបផ្ទឹម ឲ្យត្រឹមនោមឆាយ ក្នុងផែនដីអាយ មិនឆាយ

ទឹងដូច ៗ សុដណាទាំងពីរ កេសាមានក្លី ខ្មៅរញួរលើប

គន់មើលភក្ត្រា ថ្ងៃថ្ងាចង់ថើប កិលេសនាំស្រើប ព្រឺព្រួច

ពេមា ៗ សម្ពស្សប៉ះពាល់ ទឹកក្រុតរត់ដល់ កវង្គដូចគ្នា

សុទ្ធតែដំពើប ពុំដែលប៉ះពា ដល់បានកោក្ដា ស្ងៀមស្ងាត់

ដោយខ្លួន ៗ ខ្យល់ព្យុះស្ងួតស្ងប់ នាគរេងធុញថប់ មិនបង់

នៅខ្លួន តែរិទ្ធិអំណាច ដែលមានក្នុងខ្លួន បណ្ដាលបង់ខ្លួន

មុដក្នុងគង្គា ៗ ឯអគ្គក្សត្រា ទឹងនាងកញ្ញា សុគុណាថោង

ជា ព្រមព្រះឥសី សុខឥតគណនា បញ្ឈប់ទុកស្ទះ

ប៉ុណ្ណោះសិនណា ស្រួតទៅទៀតកា ឲ្យបានយល់រឿង ៗ

(បទព្រហ្មគីតិ) ឯអគ្គទ្រង់ចេស្ដា សត្វទយោពេក

កន្ទង់ ថ្នាក់ថ្នមមិនឲ្យហ្មង ផ្គងអន់អាក់ចិត្តនាងឡើយ ៗ

ទាំងពីរអគ្គមហាក្សត្រ តែងប្រតិបត្តិឥសីហើយ ពុំដែលមាន

ទាស់ឡើយ តែងបម្រើជាប្រក្រតី ៗ រីឯព្រះតាបស ទ្រង់

សប្បុរសព្រោសប្រណី អាណិតព្រះបក្រី ដបព្រះខន្ធទឹងផ្ទប

សរ ៗ ប្រមានក្សត្របួសបួង ទុកកាន់ហោងគ្រាន់ការពារ សត្រូវផងនានា ខ្មោចបីសាចនឹងយក្ស ៗ ក្នុងថ្ងៃនោះឯងនៃ ក្សត្រជៀស្ឋជ័យនឹងនាងណា ចិត្តបង់ចរលីលា ទៅរកបេះ ផលាផល ៗ មកប្រគេនលោកតា កាលនោះណាក្សត្របួស បួង នាំនាងនាដស្នេហ៍ស្ងួន ទៅបង្គំលាឥសី ៗ ព្រះមុនី បានយង់យល់ ក្សត្រនិម្មលនឹងក្សត្រី មកលាយាងទៅព្រៃ ទ្រង់អនុញ្ញាតតាមចិន្តា ៗ ទាំងពីរពង្សប្រណិប័តន៍ ក្រាបលា ថ្វាត់បរយាត្រា ទៅឆ្ងាយណាស់ហើយណា ទើបបានដល់ យល់ឈើផង ៗ ស្រោងស្រាងខ្ពស់ត្រឈៃ ខាងក្រោមនៃម្លប់ កន្ទួង មានហ្វូងបក្សីផង ប្រចិកស៊ីអស់ផលា ៗ ស្តេចនាំ ន្ហួនប្អូនស្រី ទតបក្សីនឹងព្រឹក្សា ទ្រង់ថ្លែងប្រាប់ឈ្មោះថា ន្ហួននាងមើលនូវដើមព្រីង ៗ មានសេកមានសារិកា ទំ នៅនាចិកសត្វហ៊ុង គោព្រៃជ្រកក្រោមព្រីង ប្រើសក្តាន់ ទីងផ្អើលរីវ ៗ នាងនាដនារីរត្ន ទតទៅថ្វាត់ឃើញប្រើស ឈរ អង្វរព្រះភូធរ ឲ្យស្តេចដេញចេញចាប់ហោង ៗ នាង

ទតយល់បង្គៅ ចង្អុលទៅប្រាប់ច្បាស់ច្បង ថានោះផ្លែឈើ ផង ដើមបង្គៅផ្លែច្រើនណាស់ ៗ ឯអង្គមហាក្សត្រា ឮនាង ថាទ្រង់ឮច្បាស់ យល់ផ្លែនោះច្រើនណាស់ ហើយឃើញ សត្វជ្រឹងគោងផង ៗ ហើយស្ដេចបន្ទូលថា: ដួងចិន្ដាថ្លៃ ថ្លើមបង នួននាងមើលជ្រឹងហោង ទំសំយុងក្បាលចុះណា ៗ ក្រោមដើមស្ងួនវរលក្ខណ៍ មើលឲ្យជាក់មានទាំងស្ករ រឺផ្លែ ឈើនោះណា ចូរកន្ធ្លាស្ងួនទតហោង ៗ នាងឮព្រះស្វាមី ទើបនាងស្រីធ្ងះឆ្លើយថ្លង អញ្ជើញព្រះបាទបង រកបេះផល ឲ្យធាប់ណា ៗ ឯអង្គរិទ្ធីសក្ដិ ត្ដោះព្រះកក្រ្ដទតយល់ផ្កា រំបែកទងចម្ប៉ា ពេយកេសរក្រអូបក្រៃ ៗ ពិដោរក្លិនល្ហួយល្ហប់ ស្ដេចទតសព្វអស់បក្សី ហិចហើរច្រើនពេកក្រៃ រកបំណី គ្មានឈប់ឡើយ ៗ ទើបអង្គមហាក្សត្រា នាំកន្ធ្លាទៅទៀត ហើយ ទតផ្កាពុំលង់ឡើយ ហើយចង្អុលប្រាប់នាងថា ៗ នុ៎ះហ្ន៎ផ្កាកំភ្លឹង នៅជិតទងម្រាមហត្ថា សុមអូនស្ងួនស្នេហា ចូរនាងបេះណានាងអើយ ៗ ក្សណឯនាងនាដថ្លៃ ឮស្វាមី

ប្រើច្នោះហើយ ពុំមានបង្អង់ឡើយ បេះបានមកថ្វាយកស្ដា ៗ ស្ដេចបេះអស់មង្ឃុត ទូរេនលុតសាវម៉ាវណា ប្រគល់ឲ្យធីតា ហើយបេះស្វាម្ជូព្រៃផង ៗ ហើយបេះត្រីងហុចទៅ ជាមាសពៅ នឹមទ្ទួនបង ត្រីងផ្អែមពេកណាស់ហោង ប្អូនទទួលល្អងយកសោយ នៃ ៗ នាងយល់ព្រះកស្ដា ហុចមកណាទទួលខ្ញុំ យកត្រីង ពីដៀស្ដ្ឋ័យ មកហើយនៃនាងសោយហោង ៗ រំសៀល ព្រះសុរិយា នាងទូលថានៃព្រះបង ថ្ងៃទៀបណាស់ហើយ ហោង សូមបញ្ជាស់ប្ញង់បរយាត្រា ៗ ពេលនេះល្ងមយាង ហើយ ក្សត្រត្រាណាត្រើយក្រែងលោកតា ទន្ទឹងផ្លូវយើង ណា ម្ល៉េះចាំមើលពុំលែងឡើយ ៗ ចមពង្សអង្គបេស្ដា ឮអាណាថាដូច្នោះហើយ ពិតពុំបង្អង់ឡើយ ស្ដេចនាំនាងយាង យាត្រា ៗ អរម្រែកត្រីងបណ្ដើ នាងយកទៅទូលខ្លះណា ចំស្រូតប្រញាប់ការ លុះបានដល់សាលាហើយ ៗ រៀបទុក ដាក់ហើយណា អស់ផលាពុំកន្ដើយ ប្រគេនឥសីហើយ ទុក សម្រាប់ខ្លួនឯងហោង ៗ លុះយប់ព្រះសន្ធ្យា នាំនាងផ្ទុំស្រួប

ផាម្ដង លន់លក់ឥតមួហ្ង ទាល់តែថ្ងៃរះព្រឹកព្រាង ៗ តើនចាកពីក្រឡា បន្ទំណាស្ដេចនាំនាង ចាកពីបន្ទំយាង មក គង់ក្រៅសាលាហ៉ាន ៗ ហើយនាងនាដទៅយក ផលាមក យកទៅថ្កាន ៗ ប្រគេនតាបសបាន ទទួលនាងស្រេច ហើយនៃ ៗ ទើបនាងនាដសោភា បង្គំលាវិលវិញវៃ ទៅ ហ៉ានសាលាខ្វី នៅនៃបនិត្យទឹងបាទបង ៗ ក្សត្រីនឹង ក្សត្រា រួមស្នេហាឥតមួហ្ង វៀងរាបដូចសព្វដង ហើយ តែងបម្រើឥសី ៗ ឯព្រះបាទព្រហ្មទត្ត បានស្រីវត្សរួមមេត្រី គ្រប់បីខែហើយនៃ ព្នុកព្រះទ័យនឹកគាក ៗ រលឹកព្រះបិតា នូវមាតាជាពជា បើកបន្ទូលលោមលា ថានឹមន្ទនស្ងួនស្នេហា ៗ បូប្អូនស្ងួននាងនៅ បងលាពៅទៅសិនណា នឹងទៅសួរបិតា នូវមាតាឯនាយនៃ ៗ ក្រែងស្ដេចពុំបានសុខ កើតអផ្សុក ព្រួយព្រះទ័យ ទន្ទឹងបងខ្វាំងក្រៃ ដ្បិតបងមក៣ខែហើយ ៗ បើបងទៅហើយណា ទូលបិតាឲ្យជ្រាបហើយ ថាបានប្អូន គ្រាណាត្រើយ សូមចាត់ពលសេនាផង ៗ មកទទួលប្អូនពៅ

មិត្រមាសទៅណានួនល្អង នៅជាមួយទឹងបង ឯនគរនាយ នោះណា ៗ សុគុណាថោងបានហ្ដាប់ អស់សាសព្វព្រះវាចា ក្រាបទូលព្រះភស្ដា ដោយអន់អាក់ព្រះទ័យក្រៃ ៗ តឹងណែនកន្ទុក ពេកណាស់សាឆ្អល់ឆ្អែតនៃ ផ្ទាក់ថ្មើមខ្វល់ព្រះទ័យ ស្មើរទឹងផុតដង្ហើមទៅ ៗ ទើបនាងទូលសាសង ម្ចាស់បងទុកឲ្យប្អូននៅ ហើយស្ដេចទឹងលាទៅ ឲ្យប្អូននៅតែឯកា ៗ សូមស្ដេចយកទៅផង ជាបំណាងបង ហើយណា បើស្ដេចចោលសង្សារ នោះសមប្អូនទឹងក្សិណក្ស័យ ៗ ស្ដេចលួងលោមទៅថា ឱដីរ៉ាមាសប្រិមប្រិយ៍ សូមប្អូនមាសថ្មើមថ្ងៃ នាងនៅទឹងលោកតាហោង ៗ បងទៅជាប្រញាប់ ចង់ឲ្យបាប់ណានួនល្អង ដ្បិតជើងសេះហោះផ្សងលើអាកាសលឿនលើសខ្យល់ ៗ នាងនៅទឹងលោកតាអស្វហោះមិនសល់រ៉ល់ លោកតាមិនអម្ពល់ លោកគង់យល់ចិត្តបងហើយ ៗ នាងនាងទូលសាសង ថាម្ចាស់បងជីវិតអើយ ស្លាប់រស់មិនគិតឡើយ ឲ្យតែបានទៅជាគ្នា ៗ បើស្ដេចគង់

អស្យា គួរមេត្តាយកប្អូនភ្ងា នឹងបានជួបពជា ស្តេចបិតាមាតា ផាក់ ៗ នឹងបានថ្វាយបង្គំ ក្សត្រឧត្តមទាំងពីរនាក់ កុំស្តេចស្ងួតព្រះកក្ត្រ ទុកឲ្យខ្ញុំនៅនេះឡើយ ៗ បើធ្នោះចូលប្អូនពៅ យើងនឹងទៅណាតាហើយ បើប្រោសប្រាណត្រាណត្រើយ លោកមេត្តាឲ្យយើងទៅ ៗ បន្ទូលស្រេចហើយណាទើបក្សត្រានាំឆោមឆ្ងៅ ចុះពីសាលាទៅ ដល់អាស្រមលុតដង្គំ ៗ បង្គំព្រះឥសី ព្រមគ្នានៃទាំងពីរពន្យ បីដងហើយឆោមយង់ ទ្រង់ពិតទូលដីកាថា ៗ បពិត្រព្រះបរម ខ្ញុំបង្គំលាលោកតា សូមទ្រង់ប្រោសករុណា នាងកន្និដ្ឋាសុំទៅផង ៗ ព្រះមុនីវត្តឥសី ស្តាប់សេចក្តីហើយសាសង នឹងយកនាងទៅផង ទ្រង់អំណរក្នុងចិន្តា ៗ បើស្តេចយកនាងទៅ ទោះខុសត្រូវណាក្សត្រា សន្តោសប្រោសមេត្តា គ្នាកុំព្រាឥតញាតិផៅ ៗ ឯអគ្គមហាក្សត្រាឮវាចាផ្តាំត្រឹមត្រូវ កុំព្រួយព្រះទ័យក្រូវ ទទួលទុកលើសិរសា ៗឯព្រះមហាឥសី ប្រោសប្រណីទ្រង់មេត្តា ទូន្មាននាងនាថា

នៃសុគុណថោងចៅអើយ ៗ នាងនៅត្រូវប្រយ័ត្ន ចូរប្រតិបត្តិ ណានាងអើយ កុំឲ្យខុសគ្គងឡើយ តាមក្រមក្រិត្យច្បាប់ស្រី ណា ៗ បើស្តេចសព្វព្រះទ័យ ស្រីដទៃជាសន្សរ កុំនាង ខឹងសម្បា នោះហៅខុសក្រិត្យក្រមក្សត្រ ៗ ត្រូវនាងទប់ព្រះ ទ័យ ណាស្រីថ្ងៃឲ្យស្មៀមស្ងាត់ នាងត្រូវប្រុងប្រយ័ត្ន កុំបរវា សាសង់ឡើយ ៗ មួយទៀតបើក្សត្រថ្ងៃ ទ្រង់ក្រោធក្រៃនឹងគេ ហើយ កុំនាងញុះញង់ឡើយ ឲ្យស្តេចរិតតែក្រោធាៗចូលនាង ទូលសម្រួល ឲ្យបានស្រួលព្រះទយា យកគេទុកជាគ្នា ខ្លួន កំព្រាអភ័ព្វហោង ៗ មួយសោតព្រះបិតា ព្រះមាតាក្មេកប្រាស់ ច្បង នៅគាល់បម្រើហោង ឲ្យស្តេចទ្រង់ប្រោសមេត្តា ៗ ដ្បិតខ្លួនកំព្រាសល់ ឥតបើយល់អ្នកឯណា ផ្ញើខ្លួនលើក្សត្រា ឲ្យមេត្តាប្រោសប្រណី ៗ កុំអាងប្តីជាស្តេច កុំសម្រេចចិត្ត ឡើយនៃ អាងតែខ្លួនជាស្រី ប្តីស្រឡាញ់ពុំខ្វាបឡើយ ៗ ចូរនាងចាំពាក្យតា កុំភ្លេសណាចៅតាអើយ ធ្វើតាមពាក្យ តាហើយ ចៅនឹងបានក្តីសុខា ៗ នាងលើកដៃប្រណម្យ

ថ្វាយបង្គំឱនសេរសា ទទួលបេរដីកា ទុកលើក្បាលនាង នាងហោង ៗ ស្រេចហើយពីរពង្សក្សត្រ ក្រាបថ្វាយថ្វាត់ ទាំងទ្វីសង បង្គំលាចេញហោង យាងសំដៅទីសាលា ៗ ស្តេចទឹកដល់មនោម័យ អាជានេយ្យកណ្ឌស្សពជ នឹកភ្នាម មិនហ៊ានគាជ គិតមកដល់ក្សត្រប្រាសបង្ស ៗ នេះសមស្តេច រកអញ ទឹងវិលវិញនគរហោង អស្សរាហ៍ហៀរហោះធ្វង កាត់វិលដល់ភ្នាមថ្វាត់ ៗ កាលនោះព្រះទសពល ទត យន់យល់យានហើយក្សត្រ បើកបន្ទូលប្រាប់ថ្វាត់ ថាយើង ទៅឥឡូវហើយ ៗ ប្រាប់ស្រេចស្តេចយកគ្រឿង ល្អរងរឿង កុំយូរឡើយ ស្អិតស្អាងសេះស្រេចហើយ កុំលង់ឡើយព្រះ មហាក្សត្រ ៗ លើកនាងបីត្រកង ឡើងលើខ្នងស្តេចផែល ថ្វាត់ គង់ស្រេចស្តេចប្រយ័ត្ន មិនឲ្យហោះលឿនពេក ឡើយ ៗ

(បទកាកគតិ) ដំណើរដំណាល ពីអង្គក្សត្រា ឡើងគង់សេះហើយ សេះចាំបង្គាំ ស្តេចកុំភ្ញុចឡើយ ស្ទុះ

ហោះទៅហើយ ប្រទក្សិណបាន ៗ អាស្រមព្រះមហា
ឥសីនោះណា បំផុំហើយបាន ទើបសេះហោះត្រង់ តម្រង់
ទៅបាន បុរីពជដ្ឋាន នគរនោះណា ៗ សេះហោះពីព្រឹក
ក្នុងចិត្តស្តេចទឹក គន់គិតថៃថា ស្តេចផ្តាំមិនឲ្យ ហោះលឿន
ទៀយណា គិតហើយអស្ចារ្យ ហោះសន្សឹមហោង ៗ
លង់លុះសុរិយេ រសៀលជ្រៀងជ្រេ ទើបក្សត្រប្យាស់ប្យង
ទៀនឲ្យមនោម័យ ហោះលឿនវិញហោង ទើបសេះសាសង
ទូលតបវិញថា ៗ បពិត្រអម្ចាស់ បើចង់រហ័ស សូមព្រះ
ក្សត្រា ឱបព្រះមហេសី ឲ្យខ្ជាប់សិនណា ប្រុងព្រះកាយា
ខំទ្រឹងហោះហោង ៗ សម្តេចភូមី ឮវាក្យពាជី ប្រាប់ស្រេច
ហើយហោង ឱបព្រះមហេសី ខ្ជាប់ក្រៃកន្ទុង សេះផ្ទោះឆាប់
ហោង មើលយល់បុរី ៗ សេះបន្ទាបដាក់ ឈប់ហើយ
ទ្រង់លក្ខណ៍ នាំអគ្គមហេសី ចុះចាកអស្សពាហ៍ នាកាល
នោះខ្វី ពួកមុខមន្ត្រី ឃើញមហាក្សត្រា ៗ ស្តេចបានមក
ដល់ សប្បាយរបល់ គ្រប់គ្នានោះណា សឹងតែលូនចូល

បង្គំក្សត្រា ហើយនាំអស្សា ចូលក្នុងរោងហោង ។ ឯអស់ស្រីស្នំ សៅឡឹកតូចធំ ចេញមកត្រសង ហែនារីរត្ន ទឹងស្តេចប្រាសប្បង ឡើងប្រាសាទហោង ក្នុងទែនសុវណ្ណា ។ ឯអស់មន្ត្រី ចាស់ក្មេងប្រុសស្រី មើលរាជកនិដ្ឋា ល្អទ្រង់ល្អទ្រាយ សមសក្តិណាស់ណា គ្រប់លក្ខណ៍អស្ចារ្យ លើសស្រីសួគ៌ា ។ ស្តេចមានបន្ទូល បង្គាប់បារគូ បុរោហិតជា ទឹងរាជអាមាត្យ នាំយើងយាត្រា ឡើងគាល់បិតា មាតាមហាថ្លៃ ។ ប្រាប់ស្រេចហើយណា ព្រះមហាក្សត្រា នាំនាងប្រិមប្រិយ៍ ឡើងគាល់បិតា ពួកមហាមន្ត្រី ហែព្រះចក្រី ទឹងទាំងនាងហោង ។ ស្តេចយាងបានដល់ ប្រាសាទមណ្ឌល បិតាប្រាសប្បង ក្រាបថ្វាយបង្គំ ប្រណម្យទាំងសង អស់សៅឡឹកផង គង់គាល់ក្សត្រា ។ កាលនោះព្រះបាទ សាមលនរនាថ ទឹងនាងរក្ខា ទតទៅយង់យល់ និម្មលធីតា ទឹងរាជបុត្រា មកដល់ហើយហោង ។ ទ្រង់ទឹកអរព្រួច ពន់ពោះគ្រលួច អរក្រៃ

កន្ទីង ផ្សៀតឃើញរូបនាង ឆោមឆើតណាស់ហោង លើសអស់
ស្រីផង ទាំងឡាយនានា ៗ នាងទប់ពុំបាន ហើយក្រោកទៅ
ថ្កាន ខុបបុត្រសុណិសា ជាខុមាសស្ងួន កូនល្អណាស់
ណា គឺព្រេងវាស្នា ពីជាតិមុនហោង ៗ ឯនាងសុគុណា
ថោងកៃវត្ថុគន់ បន្ទូលសាសង ខ្ញុំកើតក្នុងផ្កា ផ្កុលមាស
ជាមួង ជ្រុះពីស្បូវង ព្ពោះព្រះកន្ត្រា ៗ ព្រះបាទសាមល
ទតទៅឃងយល់ ផាក់ផាសុវណ្ណា ជ្រុះមកអំពី ព្រះស្បូវង
ណា ចោះហើយក្សត្រា បើកបន្ទូលខ្ញុំ ៗ ថាបន្ទុរក្ខា អូន
មើលចុះណា កូនប្រុសានៃ គ្រាន់តែហាមាត់ និយាយរឿង
ស្តី ផ្កុលមាសបេញខ្ញុំ សុទ្ធសុវណ្ណា ៗ កាលនោះនាង
នាដ វិបុលសុជាតិ ឮស្វាមីថា: ដុំមាសជ្រុះបេញ ពីក្នុង
ឧស្សា នៃនាង:ពោះណា ពិតប្រាកដហោង ៗ ឃើញផ្កាផ្កុល
មាស សែនល្អពេញរាស ប្រើនក្រែកន្ទីង នាងយកកាន់
មើល ជាមាសឆ្តោរហោង នាងនាដទួនល្អង ថ្វាយទៅស្វាមីៗ
រីកាលនោះណា ព្រះបាទក្សត្រា សាមលធិបតី មានព្រះ

អំណរ អរនឹងបុត្រី ទើបព្រះបក្រី សួរទៅបុត្រា ៗ កូនប្រុសបា
ទៅ បានជួបនាងនៅ នាហានឯណា បូរកូនសាសព្វ ប្រាប់
ប្រាប់បិតា ឲ្យបានដឹងការ ឥឡូវនេះហោង ៗ កាលនោះ
ព្រះបាទ ព្រហ្មទត្តនរនាថ ស្ដាប់ព្រះសាសង ព្រះវរបិតា
សាកសួរប្រោះហោង លើកហត្ថទាំងសង បង្គំទូលថា ៗ
បពិត្រកាលខ្ញុំ ក្រាបថ្វាយបង្គំ លាព្រះបិតា អស្រុពាហ៍នាំ
ហោះ ផ្សងផ្សោះទៅណា ដល់ទីព្រះមហា អាស្រម
ឥសី ៗ ខ្ញុំចូលនមស្សការ ព្រះឥសីលា ទតយល់
ខ្ញុំនៃ មានថេរដីកា សួរនាមខ្ញុំនៃ ឈ្មោះស្រុកហើយនៃ
មាតាបិតា ៗ ខ្ញុំទូលសព្វគ្រប់ ពុំមានលើសលោះ
ពាក្យពេចន៍ឡើយណា ទូលពីបំណង ចិត្តខ្ញុំប្រាថ្នា នឹងនាង
កញ្ញា ធ្វើជាមហេសី ៗ ឥសីស្ដែងស្ដាប់ អស់អារ្យសាសព្វ
រឿងរ៉ាវខ្ញុំនៃ យកនាងមកផ្សំ ផ្គុំនឹងខ្ញុំខ្ពី រួមរសមេត្រី
សព្វទិនទៅ ៗ កាលនោះព្រះបាទ សាមលនរនាថ នឹងនាង
វក្ខា ឮបុត្រាទូល សព្វគ្រប់ហើយណា ព្រះក្សត្រាទ្រង់

ព្រះអំណរ ៗ ស្តេចសព្វព្រះទ័យ សុគុណាថោនស្រី ព្រះទ័យ
ស្មោះសរ ប្រាប់អស់មន្ត្រី តូចធំដែលមក ឲ្យគិតលៃលក
អភិសេកបុត្រា ៗ ផ្សំតកូនអញបាន ស្រីវត្តកល្យាណ យក
មកហើយណា អញនឹងគិតលើក អស់រាជវង្ស ប្រគល់បុត្រា
ឲ្យសោយរាជ្យហោង ៗ ចូរឯងចាត់ចែង ធ្វើសារយ៉ាងខែង
ធ្វើផល់ស្តេចផង មួយរយម្តៃ ចំណុះយើងហោង ឲ្យនាំ
ពលផង នឹងគ្រឿងសក្ការ ៗ មាសប្រាក់អង្ករ ដំណើប
យ៉ាងល្អ នឹងទុកធ្វើជា អន្សមនំគម នំទៀននំផាល ឲ្យយក
មាន់ទា យកគោក្របី ៗ ទុកធ្វើជាម្ហូប អាហារស្រស់ស្រួប
លៀងមុខមន្ត្រី ឲ្យអស់ស្តេចរយ ដែលនាំសួយរៃ មកថ្វាយ
យើងនៃ យើងនឹងអភិសេក ៗ គ្រឿងក្អមជូរប្រែ សាប់
អាំងជៀនខ្ចី ប៊ុសស្តឹកសារម៉ាន់ ត្រូវនឹងប៊ុស្គី គោញាក់
យ៉ាងខ្លាំង អាប់សេនសម្រាំង ទុកឲ្យស្រី ៗ ៗ
ស្រាសបំណាយ ឲ្យពលនិកាយ ផឹកស៊ីរញ៉ី ឲ្យយកទាំង
ទឹក ត្នោតជូរផងនៃ ឲ្យពលប្រុសស្រី ផឹកស៊ីសប្បាយ ៗ

អាមាត្យស្តែងស្តាប់ ទទួលបង្គាប់ ធ្វើអាបុតហ្កាយ ថ្វាយ គ្រប់នគរ មួយរយម្ភៃថ្វាយ ស្តេចរាយនិកាយ ឲ្យយាងតាំង អស់ ៗ ឲ្យយកសួយរៃ ធ្វើតាមសេចក្តី ឧក្ការតាំងអស់ ផ្ញើទៅនគរ ចំណុះស្តេចស្មោះ កុំមានលើសលោះ សេស សល់មួយឡើយ ៗ

ប៉ៃរបុបទពំគោលវិញនៃ កាលក្សត្រជៀស្នជ័យ សាមលក់ពជច្បាស់ច្បង ៗ ស្តេចឲ្យក្រាលកំរាលហោង ពូកព្រៃព្រំផង ឲ្យបង់រនាំសន្ទយា ៗ ស្វេតឆ័ត្រដាំពេជ្រ កឹថ្វា បិទមាសក្លឹទ្នាល ឡើងក្រហមប្រាលពេកហោង ៗ ក្រោមស្វេតឆ័ត្រឥតម៉ង ស្រេចហើយច្បាស់ច្បង ឲ្យរៀប ចាំហ្មុនណា ៗ បាយមុនរៀបចម្រុះផ្កា ជាឈូករត្នណា ចន្ទោះបាយមុនរៀងទៅ ៗ សែនក្ងាន់ចម្រុះពងរ៉ូវ ឆត្រួត ច្រើនក្ងៅ ពីរដួរអមទិសអភិសេក ៗ ឲ្យបុត្រស្អិតស្អាងល្អ ប្លែក សុណាំសា យ៉ាងឯក ឲ្យទ្រង់គ្រឿងគ្រប់ច្រើនផង ៗ ព្រហ្មទត្តបៃតងផូរផង់ សុគុណាថោងហោង ប្រដាប់សុទ្ធថ្ងៃ

អស្ចារ្យ ៗ ព្រហ្មទត្តស្ដេចទ្រង់សង្វារ សុគុណថោនណា
ខ្សែដាំពេជ្រថ្វាសួន ៗ ព្រហ្មទត្តទ្រង់ភូសាហោង សុគុណ
ថោនទួនល្អន ទ្រង់ស្បៃលេចផ្កាទិពមាស ៗ ក្បាច់ក្បីវវន្ទួ
ពេនពាស សុទ្ធផ្កាទិពមាស ភ្លឺផ្លេកលលាមអស់អង្គ ៗ
ព្រហ្មទត្តទ្រង់មកុដកែវខ្វង់ ភ្លឺផ្លេកយល់យង់ ដូចអង្គឥន្ទ្រា
ថ្ងៃថ្វា ៗ នាងទ្រង់រត្នកែវសុវណ្ណា ដូចសច្ចា ល្អឆើមលុប
លើសអស់ស្រី ៗ ស្ដេចទ្រង់ទម្រង់យ៉ាងថ្មី ត្បូងពេជ្រយ៉ាង
ថ្ងៃ ទឹងត្បូងស្របគាន្ទនោះហោង ៗ នារីទេវីស្នេហ៍ស្នង ពាក់
ទម្រង់ហោង ដាំត្បូងមណីរត្នភ្លឺថ្លា ៗ ភ្លឺប្រុះធ្លុះអង្គធីតា
ស្អាងស្រេចហើយណា ទើបព្រះបិតាដៀស្ដស័យ ៗ នាំបុត្រ
ទាំងពីរនោះនៃ ឡើងគង់លើញ គ្រែទេនយ៉ាងថ្ងៃសុវណ្ណា ៗ
ឯក្សត្រទាំងរយឯកា យល់អង្គក្សត្រា គាន់គាំងហ៊ាំងកាំង
ភិតភ័យ ៗ សម្ដីងពុំដាក់នេត្រនៃ ក្ដេចខ្លួនទទៃ ដោយរិទ្ធិ
អំណាចចេស្ដា ៗ ព្រះបាទសាមលបិតា ឲ្យអស់សេនា - មាត្យ
មុខមន្ត្រីបតី ៗ ព្រាហ្មណ៍ព្រិទ្ធបណ្ឌិតគរី បារគូមន្ត្រី ព្រះ

ញាតិព្រះវង្សពង្សា ៗ ចូលពេញកកកុញត្រៀបត្រា ក្រុងសព្វ
គាសា ពិទូរ្យផូរ្យផង្គ្រឹធង ៗ ប្រគំរងំកន្ទុំ អស់
ទាំងក្រុងផង លេងដោយគាសាទទៃ ៗ ស្ចូរសំរងំ
ពេកក្រៃ ស្ងួតតែរបះល្បី ស្មាដៃយ៉ាងឯកអស្ចារ្យ ៗ
លុះដល់ព្រឹកព្រាងហើយណា ហៅហោរម្ហា ឲ្យមើលបុក្ស-
ពារធាយា ៗ ហើយឲ្យរាជបុត្រា ឡើងគង់លើបា-ល្លង្ក
ក្រោមស្វេតឆត្រហោង ៗ នាងសុគុណាថោងទួនល្អង ឲ្យ
ឡើងគង់ហោង បុស្សបុកយ៉ាងល្អថ្វីថ្វា ៗ ដោតជ័យល្អក្រៃ
សោះសា សេះ៥ហោក គោះគងយកពេលាហោង ៗ
ទោមយង់ពីរពង្សឥតហ្មង ទុនសារសាហោង ក្រាបថ្វាយបង្គំ
បិតា ៗ បីដងស្រេចហើយក្សត្រា ទឹងនាងធីតា បង្គំព្រះមាតា
ហោង ៗ ព្រះបាទសាមលប្រាស់ប្រាង យកពិពលផង
បង្វិលឲ្យរាជបុត្រា ៗ សូរេចស្រាប់ស្រេចហើយណា ទើបមហា
ក្សត្រា បង្គាប់ឲ្យអស់ព្រាហ្មណ៍ធំ ៗ ឲ្យសូត្រពរជ័យគឹក
កង ពួកញាតិវង្សផង បាចផ្កាស្លាថ្វាយគ៏ងគាប់ ៗ យកទ្រព្យ

មាសពេជ្របំណាច់ កែវកងសម្រាប់ បូលចង់ស្តេចទាំង ទ្វេហារ ៗ ស្រេចហើយព្រះបាទក្សត្រា សាមលបិតា លើកយកអស់រាជសម្បត្តិ ៗ លើកថ្វាយបុត្រាមហាក្សត្រ សោយរាជសម្បត្តិ គ្រប់គ្រងតពីបិតា ៗ ស្រេចហើយព្រះបាទក្សត្រា ឲ្យលើកអាហារ ជប់លៀងស្តេចរយឯកហោង ៗ លៀងទាំងព្រះញាតិវង្សផង ល្បែងលេងគឹកកង ជារាជកីឡា ក្សត្រថ្ងៃ ៗ សូរ្យ័ត្រែយោលទោងខ្ទាំងក្រៃ សៀកបិនយូទក្តី សៀកសៀមពុល្ស៍អស្ចារ្យ ៗ ម៉ូតូឡើងជញ្ជាំងណា គួរសើបអស្ចារ្យ ទឹងពួកកីឡាខ្ទាំងក្រៃ ៗ កុនលោនយីកេ អាយ៉ៃ លេងពេញតែផ្ទៃ រាំងក្រៅកំផែងត្រៀបត្រា ៗ ស្រីប្រុសកំឡោះហ៊ឺហា ឪតស្រីពួកផ្កា ប្រជ្រៀតគ្នាមើល កកកុញ ៗ ពិធីនេះធ្វើមិនសុញ ជ្បិតស្តេចមានបុណ្យ កំណោត់៧ទេវ ៗ សូរបស្រាប់ស្រេចហើយណា ស្តេចរយឯកា បង្គំក្រាបលាទៅហោង ៗ ញាតិវង្សបង្គំលាផង ទៅជំណាក់ហោង គ្រប់គ្នាទាំងជាមួង ៗ ព្រះបាទព្រហ្មទត្តប្បាស់

ប្អូន ស្ដេចសោយរាជ្យស្នង ជំនួសព្រះវរបិតា ៗ សឹងសុខឥត
ទុក្ខភយា ស្ដេចរយងកា ខ្ជប់ខ្ជាប់អំណាចបារមី ៗ អស់ពួក
នាម៉ឺនមន្ត្រី កោតខ្លាចជៀសជ័យ ពុំហ៊ានឲ្យខុសគន្លង ៗ
ស្ដេចគង់ប្រាសាទឥតម៉ង រួមរក្ខនូនល្អង សុគុណថោងកែវ
កនិដ្ឋា ៗ ប្រតិបត្តិមាតាបិតា ក្សត្រទាំងទ្វេហារ ពុំមានឲ្យ
ខុសព្រះទ័យ ៗ ឈប់ស្ទះពីនេះសិននៃ ថ្លែងពីធិបតី សម្ដេច
ម្រិន្ទឥន្ទ្រា ៗ ឃើញស្ដេចព្រហ្មទត្តពុំងា សុគុណថោងជា
ប្រតិបត្តិនូវអ្នកមានគុណ ៗ ទេវិន្ទប្រមើលគយគន់ ឃើញ
ស្ដេចមានបុណ្យ នឹងតាំងសុគុណថោងណា ៗ នឹងបានជា
ពុទ្ធមាតា នឹងជាបិតា ព្រះពុទ្ធឯក្រោយនោះនៃ ៗ
ព្រះឥន្ទ្រទ្រង់ជ្រាបវៀងវៃ ថាពោធីថ្ងៃ ស្ថិតនៅស្ថានតុសិតា ៗ
នឹងអង្គអនុជនោះណា បានរួមមាតា មូលមួយនឹងពោធិ
ថ្ងៃ ៗ ជ្រាបហើយព្រះឥន្ទ្រហោះវៃ រំពេចដល់ទី
កិមានស្ថានតុសិតហោង ៗ ដល់ហើយឥន្ទ្រាសាសង
ថាខ្ញុំនេះហោង មកអញ្ជើញអ្នកលីលា ៗ ចុះចាកពីស្ថាន

សួគ៌ា ទៅចាប់ផ្ទៃនា ជម្ពូទ្វីបនោះឯងនៃ ។ បដិសន្ធិក្នុងផ្ទៃ
សុក្រជាងនៃ នៅការបុរីនោះហោង ។ ពោធិសត្វ
ត្រេកអរកន្ទង មានបន្ទូលសួង ទៅនឹងសម្តេចឥន្ទ្រា ។
ថាបើខ្ញុំទៅនៅនា ជម្ពូទ្វីបជា មនុស្សលោកឯទាយនោះ
ហោង ។ បើខ្ញុំកើតទុក្ខជួយផង ឲ្យរួចរម្ងង អំពីទុក្ខភ័យ
នោះណា ។ ព្រះឥន្ទ្រទទួលពាក្យថា បើហេតុយ៉ាងណា
នឹករកខ្ញុំទៅជួយហោង ។ និមន្តឲ្យប្រុតផ្គង ចុះចាកជាម្តង
ទៅចាប់បដិសន្ធិ ។ ពោធិសត្វទទួលពាក្យពី ឥន្ទ្រាមុនី ក៏
យាងចូលផ្ទៃនាងហោង ។ កាលៈពោធិសត្វច្បាស់ប្បង ចូល
ចាប់ផ្ទៃហោង នាងផ្ទុំទ្រង់សុបិនណា ។ យល់ដូចអង្គព្រះ
ភស្តា បានធត្រ័យណា អំពីព្រះឥន្ទ្រឲ្យមក ។ រំកាយស
ដូចពពក កំពូលធត្រូយក កែវសូរិកាន្តល្អក្រៃ ។ ឃើញ
ដូចព្រះបាទក្សត្រថ្ងៃ បាំងទាំងយប់ថ្ងៃ មានម្លប់គ្រប់ទាំងផែន
ដី ។ កំដៅនៃសែងសូរិយ៍ ពុំក្តៅដល់ដី ត្រជាក់អស់ក្រុង
ភាព ។ ហើយនាងតើនឡើងមម្មា ឯព្រះរាជា តើនឡើង

ស្រកគ្នោណា ។ នាងទូលសុបិនក្សត្រា ឲ្យស្វាមីណា
ស្តេចបានទ្រង់ជ្រាបព្រះទ័យ ។ ទើបស្តេចមានបន្ទូលទៅ ទ្រង់
ប្រើទាសី ឲ្យទៅហៅហោរមកណា ។ ទាសីទទួលឱង្ការ
ហើយលើកហត្ថា បង្គំលាចរចេញទៅ ។ ដល់ផ្ទះហោរ
ហើយចៅហៅ ស្តេចឲ្យហោរទៅ កុំបីបង្អង់យូរឡើយ ។ ឯ
ហោរនោះបានឮហើយ ពុំបង្អង់ឡើយ ចាប់យកក្តារឆ្នួនដី
ស ។ ទៅតាមទាសីដែលល្អ នាំមុខចេញចរ ទៅដល់បង្គំ
គាល់ហៃ ។ កាលនោះព្រះបាទជៀស្ឋជ័យ ឃើញហោរ
ហើយនៃ ទ្រង់ប្រាប់សុបិននោះហោង ។ ហោរលើកហត្ថា
ទាំងសង ថ្វាយបង្គំហោង ហើយយកក្តារឆ្នួនដីស ។ គូស
វាសបូកឡាប់បោះបរ សេស៥បារ ប្រាកដបានបុត្រត្រាណា
ត្រើយ ។ ហោរទូលស្តេចទ្រង់ជ្រាបហើយ បុត្រប្រុសត្រាណា
ត្រើយ មានរិទ្ធិអំណាចចេស្តា ។ សុបិនឃើញឆត្រនោះណា
គឺពជបុត្រា ព្រះឥន្ទនិមន្តមកហោង ។ ឆត្រនោះធំណាស់
កន្ទង់ បុត្រាច្បាស់ច្បង អំណាចលើសលុបលោកា ។

រីងក្រោយផងណា ដូចពាក្យ ទឹងមានអនុជមួយផង ៗ ក្រាប
ទូលសូមទ្រង់ជ្រាបហោង មានរិទ្ធិកន្លង ពួកជាងគេអស្ចារ្យ ៗ
ព្រះបាទព្រហ្មទត្តក្សត្រា ឮហោរទូលថា: ជ្រាបហើយទ្រង់អំ-
ណរក្រៃ ៗ ឲ្យយកទ្រព្យមានដំឡៃ ខៀនខោអាវស្បៃ
ប្រទានឲ្យហោរនោះហោង ៗ ស្តេចឲ្យពួកស្នំស្រីផង ថែទាំ
នួនល្អង ជៀងពបដពបទៅណា ៗ ហេតុតែពង្សពោធិសម្ភារ
ទៅក្នុងគភ៌ណា ឥតមានឲ្យព្រួយឡើយនៃ ៗ លុះគ្រប់ខែ១០
ស្រស់ស្រី ទន់សព្វសរសៃ ស្រយុតអស់អង្គកាយា ៗ
ទើបនាងទូលមហាក្សត្រា ទ្រង់ជ្រាបហើយណា ស្តេចឲ្យហៅ
អស់ស្នំផង ៗ ឲ្យទៅហៅឆ្មបជាមួង ឲ្យមករឹងផ្តង ប្រចាំ
ជានិច្ចហើយណា ៗ លុះដល់ព្រឹកព្រាងសុរិយា រះពេញវង្ស
ណា ទើបបានប្រសូតរួចហោង ៗ ទទររឹងឈឹកន្ទង
សព្វសរសៃផង ស្រយង់ស្រយុតកាយា ៗ ហេតុតេជះបុណ្យ
បេស្តា ទេពនិមន្តណា កក្រើកអំពើតខ្វាំងក្រៃ ៗ អម្រិន្ទ
ទេវិន្ទកោសីយ យកព្រះទន្លដ័យ មកថ្វាយកុមារស្រេច

ហើយ ៗ កាលព្រះឥន្ទមកដល់ហើយ ស្រីវត្តបាន
ស្បើយ អន់ឈឺផ្ទឹក្នុងប្រាណ ៗ អស់ទាំងព្រះញាតិ
សន្ដាន ៗ នឹងមាតាប្កាន បិតាស្ដេចយាងមកនៃ ៗ ត្រូវ
ពេលទោឃសត្វថ្ងៃ ស្ដេចយាងចាក់ផ្ទៃ ប្រសូតរូបចេញមក
ណា ៗ ព្រះឥន្ទទ្រង់ប្រែកាឡា យកព្រះខ្លួនថ្វា ថ្វាយ
អគ្គរាជបុត្រកុមារ ៗ ឯជ្ចបមើលឃើញកុមារ កាន់ខ្លួន
សប្បា ស្បានថាសំពលមកផង ៗ ក្រាបទូលឲ្យស្ដេចប្រាប
ហោង បុត្រមានខ្លួនផង ត្រេកអរកន្ទង់ពេកក្រៃ ៗ
ឲ្យយកពានមាសមកនៃ ហើយព្រះជៀស្ល័យ យកទៅ
តម្កល់ព្រះខ្លួន ៗ ឲ្យស្នំណាបទឹកអប់កាន់ កុមារដាក់ស្ពាន់
ផ្ញុំលើកប្រមាលសោកា ៗ ឯនាងស្រីវត្តជាយា ស្រង់ព្រះគង្គា
ស្ងួរជ្រះស្រាប់ស្រចហើយហោង ៗ ពេទ្យហ្មយកឱសថផង
ចាក់ថ្វាយនាងហោង ឲ្យក្សត្រីទ្រង់សុខា ៗ

បែបបទកាក្ករ ពីអគ្គកុមារ សោយច្បាស់ច្បង កាល
ស្ដេចប្រៀបស្ដុក អស្តារព្រួកក្នុង ក្រគកជាមួង ដល់ស្ពាន

សួគ៌ា ៗ ទេព្តាសព្វស្ថាន និត្យនៅពុំឃ្លាន ហោះមកម្នីម្នា
អស់ពាន់ទេវបុត្រ ចុះចាកសួគ៌ា មកជួបជុំគ្នា ទីឯព្រះឥន្ទ្រ
ហោង ៗ បង្កើតអស្ចារ្យ សព្វសារធុការ ពេកពន់គន្ធ
ផ្កាបាចបាចមាសប្រាក់ ធ្លាក់ចុះមកហោង អស់ផ្កាកីឆ្គ៌ ពាស
ពេញប្រថពី ៗ ស្រេចហើយព្រះឥន្ទ្រ ចមហៅទេវិន្ទ នាំ
គ្នាបរលី ហោះទៅកាន់ស្ថាន សុខសួគ៌សម្ពី ធាត់អស់ពាំទី
នោះស្ងប់ស្ងាត់ហោង ៗ កាលនោះព្រះធាត ព្រហ្មទត្តនរ-
នាថ ក្សត្រកក្កុត្តប្រាសប្បន៍ កាលទាន់ប្រសូត កុមារជាម្ដង
គ្រប់ប៉ៃថ្ងៃហោង រៀបបើកនេត្រា ៗ ស្ដេចឲ្យរៀបគ្រប់
ប្រដាប់សែនជប់ គ្មានខ្វះអ្វីណា ជួបជុំញាតិវង្ស ពូជពង្ស
វង្ស ព្រះវរមាតា - បិតានោះហោង ៗ ឲ្យលើកបំណី
ពិសេសពិសី ពិសារគន្ធ៍ សែនតាមសណ្ដាប់ ច្បាប់បុរាណ
ហោង ស្រេចបានបំផង បង្វិលពពិល ៗ ផ្ញើប
ស្រេចហើយ ពិតពុំលង់ឡើយ ឥតមានមន្ទិល ហើយ
ឲ្យហៅហោរ ថ្វាយនាមពពិល កុមារទេវិល ទ្រង់ព្រះ

នាមអ្វី ? ។ ហោរក្រាបទូលថា បពិត្រក្សត្រា នរេន្ទ្រ ធិបតី កាលរាជបុត្រ ប្រសូតចេញខ្ចី ថ្ងៃពេញបុណ្ណមី បុក្សល្អអស្ចារ្យ ។ ថ្វាយតាមសុបិន ទី ១ នោះសិន ឃើញឆ័ត្រនោះណា ព្រះឥន្ទឲ្យមក ដល់អគ្គក្សត្រា ថ្វាយនាមកុមារ ហៅជ័យសូរវង្ស ។ កាលនោះ ព្រះបាទ ព្រហ្មទត្តនរនាថ ជាក្សត្រពូជពង្ស បាន ស្តាប់ហោរថ្វាយ ព្រះនាមបុត្រទ្រង់ ហៅជ័យសូរវង្ស កុមារថ្វាថ្ងៃ ។ បានសេចក្តីសុខ ឥតមានកើតទុក្ខ ព្រួយ ហេតុអ្វីនៃ សឹងបានសុខា ជាអាចិន្ត្រៃយ គ្មានសត្រូវអ្វី មកបៀតបៀនឡើយ ។ ស្តេចទ្រង់បង្គាប់ ឲ្យគិតកយកប់ រកមេទ្ទំហើយ ឲ្យមានរូបឆោម សក្តិសមត្រាណត្រើយ ពូជ ពង្សល្អហើយ ថ្កើងយសសក្កា ។ ឲ្យស្តាប់សំដី សូរសំឡេង នៃ ដូចសត្វសារិកា និយាយពីរោះ លួងលោមបុត្រា មើលដោះផងណា ល្មមធ្វើមេទ្ទំ ។ រកដោះវៃត្យាញ ក្បាលឡើងក្រអាញ ពីគល់មូលក្បំ ឡើងសមរៀងរៀវ មើល

នៅសក្តិសម ឲ្យផ្ញើមេនុំ បំបៅបុត្រា ៗ ឲ្យបានប្រាំនាក់
មានរូបសមសក្តិ បម្រើបុត្រា កាលនោះសេនីយ ក្រាប
លាយាត្រា បានស្រីហើយណា ទាំងប្រាំនាក់ហោង ៗ
មុខមូលក្រឡង់ ចិញ្ចើមឡើងខ្ចង់ គួរឲ្យស្នេហា សមផ្ញើមេនុំ
គ្រប់គ្រងរក្សា ម្ចាស់ក្សត្រថ្លៃថ្លា ពិតប្រាកដហើយ ៗ កិលៀង
ក្រមុំ អកយាយតាស់ខុំ មេនុំល្អហើយ បម្រើក្សត្រា
សាន្តសុខឥតស្បើយ បំណារយូរហើយ ឥតមានទុក្ខា ៗ
អស់មុខមន្ត្រី ស្តេចយេឯកក្តី សឹងសុខណាស់ណា តែង
តែដឹកនាំ សួយរៃរាជសារ មកថ្វាយក្សត្រា ពុំដែលខាន
ឡើយ ៗ លុះព្រះកុមារ ជ័យសូរវង្សា ចម្រើនធ្នាំហើយ
បានពរវស្សា នាងនាដត្រាណត្រើយ ទ្រង់គិតទៀតហើយ
ដោយមានមេវបុត្ត ៗ ដោយពួកទេវតា អញ្ជើញត្រៀបត្រា
ឲ្យស្តេចចប្យុត មកចាប់កន្ទ្រៃផ្ទៃ ជាស្រីឆ្នើមផុត នាងដឹងមាន
បុត្រ ទ្រង់គតកំទៀតណា ៗ ឯនាងសុគុណ ហោងដឹងពីមុន
តាំកន្ទ្រកាយា កាលទ្រង់គិតនៃ ជ័យសូរវង្សា ញាក់កន្តុកាយា

សោយពុំបានឡើយ ៗ នាងទូលក្សត្រា ឲ្យជ្រាបកិច្ចការ
ថាមានគភ៌ហើយ ស្ដេចត្រេកអរក្រៃ គ្មានអ្វីផ្ទឹមឡើយ
ទើបក្សត្រត្រាណត្រើយ ព្រះព្រួចព្រះទ័យ ៗ ទើកពីពាក្យ
ហោរ តាយត្រូវប្រមើល ថានាងនាងនៃ មានបុត្របន្ទាប់
ព្រាណប្រុសប្រពៃ ជាអនុជនៃ ជ័យសូរវង្ស ៗ ស្ដេច
ឲ្យអស់ស្នំ អកយាយចាស់ទុំ ចោមចាំរក្សា គិតនាង
លុះដល់ គ្រប់១០ខែ នាងនាថពីតា ឈឺព្រះឧទរ
ស្ដេចទ្រង់ជ្រាបហើយ តោតពុំលង់ឡើយ ឲ្យហៅឆ្មបមក ជំ-
ណឹងជ្រាបដល់ បិតាមារ មាតាចេញចរ ជួបជុំគ្នាហោង ៗ
លុះដល់ស្ងួហោ ថ្ងៃរះហើយណា តេញវិជ្ជមិត្តហ្វុង នាងនាថ
ប្រសូត រួចស្រេចហើយហោង មេនំស្នំផង ជួតទឹកកុមារ ៗ
ខ្វះយកព្រះពស្ត្រ ចំណងស្រស់ មកត្រងហើយណា ស្នំខ្វះ
ទទួល ព្រះកុមារ ទ្រង់ឲ្យផ្ដេកណា លើកប្រាលហោង ៗ
ឯជាយា នាងនាថសោភា អស់ស្រីស្នំផង យកទឹកឲ្យស្រង់
ស្ងួតរួចហើយហោង ទើបព្រះញាតិផង បង្គំលាទៅ ៗ

ក្រោយមកបថ្ងៃ ព្រះបាទជៀស្គជ័យ ឲ្យរៀបតម្រូវ ធ្វើរាជពីធី
បើកនេត្របុត្រពៅ រិលពពិលទៅ ដប់ប្រាំបួនដុំ ៗ សម្ដេចឥសី
កត្តធិបតី ថ្វាយនាមព្រះបរម លក្ខណ៍សូរវង្ស រិទ្ធិក្សក្រុះកុំ
ជាតិជាពូជពង្ស ក្រសត្រហើយ៖ហោង ៗ ទើបព្រះអយ្យកា
អយ្យកោនោះណា ទឹងព្រះញាតិផង បូរបង់ហត្ថា ថ្វាយ
ពរគឹកកង់ រូបស្រេចម៉ត់បាន្ន ថ្វាយបង្គំណា ៗ ស្ដេចឲ្យ
រើសរក មេនុំ៥មក បំបៅកុមារ ឲ្យមានសក្ដិសម ដូច
សូរវង្ស ជាព្រះជេដ្ឋា កុមារនោះហោង ៗ ឲ្យរកកិលៀង
ក្មេងប្រុសបម្រៀង លួងបុត្រពីរផង ឲ្យបានប្រាំរយ បម្រើ
បុត្របង្អង់ ប្រាំរយទៀតហោង បម្រើបុត្រពៅ ៗ រីអស់
សេនា ចាត់តាមគាផ្ញា រកបានគ្រប់កូរ បំនួនមួយពាន់
ក្មេងៗស្រនៅ ដឹកនាំយកទៅ ថ្វាយព្រះធិបតី ៗ ស្ដេច
ឲ្យទៅយក គាវខាខៀនមក ប្រទានផាប់ខ្ទី គ្រប់ទាំង
១ពាន់ ទើបព្រះនរបតី ប្រើឲ្យទាសី នោះវាំនាំទៅ ៗ
បន្ទូងកុមារ ជ័យសូរវង្ស លក្ខណ៍សូរវង្សពៅ មានក្មេង

ប្រាំរយ នៃបុត្រមួយកូវ ដូចនឹងបុត្រពៅ ក្មេងប្រាំរយដែរៗ ហើយស្ដេចបង្គាប់ ហៅជាងទងមក យកមាសទៅផែ ធ្វើគ្រឿងករណៈ គុបតែងតាមតែ ចិត្តបុត្រស្នាលស្នេហ៍ ទាំងពីរអង្គារ ៗ ទើបស្ដេចឲ្យយក មាសនព្វគុណមក ឲ្យជាងនោះណា ជាងទទួលយក ពីមហាក្សត្រា ហើយជាងរចនាសិតធ្វើថ្វាយហោង ៗ ជាងធ្វើសង្វា កងពាក់បាត្ដា កងបាទាផង ធ្វើបន្ទុកក្បាំងណា សែនល្អម៉ត់ហ្មង កុមារពីរផងពាក់ហៅសែនសម ៗ ឯអានុជពៅ បំណោរលង់ទៅបានបីពិតពុំ វិស្វាស្រេបហើយ បេះដើរលុំ ដួលហើយស្ដេចយំ មេនុំលួងក្សាម ៗ ព្រះបាទព្រហ្មទត្ត ទតទៅបុត្រត្ន ទាំងពីរស្លូតស្ងៀម ទតជ័យសុវណ្ណ ទ្រង់បែរងាកក្សាមសរសើរស្ងប់ស្ងៀម ថាបុត្រល្អក្រៃ ៗ ទតលក្ខណ៍សុវណ្ណដោយកើតទើសទ្រង់ ល្អល្អះប្រពៃ អស់អង្គកាយកើតងាយណាស់នៃ ស្ដេចសព្វព្រះទ័យ នឹងរាជបុត្រា ៗ ស្ដេចទៅត្រកង បុត្រទាំងពីរហោង ទៅលេងឯណា មាន

ព្រះបន្ទូល មធុរផ្តាំថា៖ បុត្របង្ស៍ទៅណា នាំប្អូនទៅផង ៗ

កុំទៅតែឯង នាំប្អូនទៅលេង ឲ្យមូលគ្នាហោង មើលថែទាំ

ប្អូន កុំឲ្យមានម៉ង ឲ្យមូលគ្នាហោង តាមពាក្យបិតា ៗ

ហើយទ្រង់ផ្តែផ្តាំ លក្ខណ៍សួវង្សទាំ សំដីបិតា បើបងទៅ

លេង ក្នុងទីស្ថានណា បូរកូនយាត្រា ទៅតាមគ្នីគ្នា ៗ

វេលានោះណា ពីរពង្សកុមារ លើកដៃវន្ទា នឹងបរចេញ

ផ្គង ទតមើលសួនផ្កា សូមទ្រង់ករុណា ឲ្យកូនទៅហោង ៗ

នាំអនុជនាថ យាងចេញគគាត ដូចរាជសីហ៍ធំ បណ្តើរ

គ្នាទៅ សំដៅជាម្តង ដល់មាត់ហោង បង្គំក្រាបលា ៗ

នាងនាដឌុនឌុប ប្នាក់ប្អូមក្រសោប បុត្រទាំងពីរណា

បរោសអន្អើល សាយសព្វកាយា ថៃថើបកន្ត្រា បុត្រទាំង

ពីរហោង ៗ ឯលក្ខណ៍សួវង្ស ឃ្លានបៅពេកពន់ ហៅ

មេនុំហោង មកដល់អ្នកបៅ មេនុំជាម្តង ជ័យសួវង្សបង

នាំអនុជនៃ ៗ លុះបៅឆ្អែតហើយ ពិតពុំលង់ឡើយ នាំគ្នា

ចេញខ្ញុំ ឯអស់ភិលៀង តាមហែច្រើនក្រៃ ដល់សួន

បញ្ចាំង ស្រាប់ស្រេចហើយហោង ៗ

ប្រែបទភុជង្គលីលា កុមារទ្វេហារ ចរចេញទៅ

ហោង ៗ ឯអស់កិលៀងអឹងកង ហៃកុមារហោង ក្រសាល
រកផ្កា ៗ រីឯជ័យសូរវង្សា នាំអនុជណា ទតអស់ផ្កាផង ៗ
លក្ខណ៍សូរវង្សដើរតាមបង ទតអស់ផ្កាផង ក្រសាល
សប្បាយ ៗ យល់អស់ផ្កាផងទាំងឡាយ កិលៀងបេះថ្វាយ
ត្រេកអរកន្លង ឯលក្ខណ៍សូរវង្សសាសង លើកបង្ហាញបង
ថាផ្កានេះនែ ៗ ឈ្មោះអ្វីប្រាប់បងជៀស្ឋជ័យ ជ័យសូរវង្សនែ
ប្រាប់ទៅប្អូនថា ៗ អូនអើយនេះហៅផ្កាច្បា នេះផ្កាចម្ប៉ា
ណាអ្នកមាសបង ៗ ឯលក្ខណ៍សូរវង្សសួរបង ថាផ្កានេះហោង
គេហៅផ្កាអ្វី ៗ ជ័យសូរវង្សប្រាប់ទៅខ្ចី ថាផ្កានួនស្រី នោះ
ណាមាសបង ៗ ឯអស់ទាំងកិលៀងផង ហៃកុមារហោង
ក្រសាលសប្បាយ ៗ ខ្លះច្រៀងខ្លះបេះផ្កាថ្វាយ ខ្លះរាំកែក្រាយ
លូកលផ្កាប់ផ្ការ ៗ ហើយធ្វើជាដួលផ្កាប់ផ្ការ ទាំងពីរកុមារ នឹង
កិលៀងហោង ៗ សើចស្រួលសប្បាយអឹងកង លុះល្ងាច

បណ្ណាល័យជាតិ

ហើយហោង វិលវិញទៅកា ៗ លុះដល់ប្រាសាទហើយណា
បង្គំមាតា ស្រាប់ស្រេចហើយហោង ៗ កាលនោះនាងនាដ
នួនល្អង សុគុណាថោងហោង ទតទៅយន់យល់ ៗ បុត្រគ្រួ
ឆោមឆើតនិម្មល មេនុំពល់ នាងទៅត្រកង ៗ បីលក្ខណ៍-
សូវង្សឡើងហោង ថើបហើយសាសង សួរទៅបុត្រថា ៗ
កូនពៅទៅលេងឯណា ប្រាប់ម្តាយផងកាំ ណាកូនថ្លើម
ថ្លៃ ៗ កុមារថ្លៃថ្លាលើកដៃ បង្គំទូលថា ថាលេងសួនបុប្ផា ៗ
គិលៀងបីបមកុមារ បំបៅហើយណា បញ្ចុកព្រះស្ងោយ ៗ
ថ្នាក់ថ្នាយកុមារស្រេចហើយ ពិតពុំលង់ឡើយ នាំលេងជាម
មួង ៗ ទះដៃច្រៀងបន្ទន់ផង សប្បាយអឺងកង រាល់ថ្ងៃ
ទៅខែ ៗ ព្រះបាទព្រហ្មទត្តជៀវក្ស័យ សុគុណាថោងនៃ
សឹងសព្វព្រះហា — ៗ — បុទ៍យននឹកជកុមារ ថ្នាក់ថ្នម
រក្សា មិនឲ្យមានហ្មង ៗ និទាននេះស្ទេះសិនហោង ទីនថ្លែង
សាសង ពីក្រុងយក្សា ឈ្មោះវិរុឡ្វមេឃនោះណា ជា
ស្តេចយក្សា ថេរបិតនិត្យនៅ ៗ ហេមវ័នគារនោះគូរ ក្រុង

យក្ខបិតទៅ នគរនោះណា ៗ មានទាំងពលច្រើនណាស្ង
សែនលានកោដិណា ដុំដាប្រក្រតី ៗ ស្តេចមានអនុជមួយ
នៃ ឈ្មោះនាងសម្ពុទ្ធី ឆោមឆើតឆាយា ៗ ឯអង្គទ្រង់
ទ្រាយនាងណា ដូចទេពកញ្ញា នៅត្រៃត្រឹង្សហោង ៗ
មានទាំងអស់ស្តេចយក្ខផង ពុំហ៊ានប៉ុនប៉ង យកធ្វើ
ភរិយា ៗ ខ្លាចរិទ្ធិខ្លាចបុណ្យសម្ភារ វិរុល្ហមេឃជា បងនាង
នោះនៃ ៗ ឯវិរុល្ហមេឃជៀស្ឋជ័យ យល់ប្អូនជាស្រី ពុំមាន
ប្ដីឡើយ ៗ ក្រុងយក្ខយល់ដូច្នោះហើយ ពុំទុកប្អូនឡើយ
ក្រុងយក្ខយកទៅ ៗ ថ្វាយព្រះឥស្សរចមហៅ ស្ថានកៃលាស
គួរ ធ្វើទេពីហោង ៗ ឥស្សរស្តេចមានស្នេហ៍ស្ងួន យល់
រូបនាងហោង ឆោមឆើតពេកក្រៃ ៗ ទុកជាសម្រាប់ក្សត្រថ្ងៃ
គង់គាល់សព្វថ្ងៃ ជាសម្រាប់ហោង ៗ ឯវិរុល្ហមេឃជាបង
លាវិលវិញហោង ទៅថ្កនកាក ៗ ហោមវ័ន្តសកាន់គង់
ជា សុខឥតភយា ដរាបរៀងទៅ ៗ ឯនាងសម្ពុទ្ធីនិត្យនៅ
យូរបានតិចទៅ ឃើញអស់ទេវតា ៗ ឡើងគាល់ព្រះ

ឥស្សូក រូបល្អណាស់ណា ទប់ចិត្តពុំបាន ៗ ហើយប្រឹងសម្លឹង
មើលព្រាណ ទេព្ដាដឹងជាន ជានាងសម្ងំ ៗ មានចិត្តប៉ងចាប
បេត្តី រួមរក្សមេត្រី នឹងអង្គអាត្មា ៗ ទេព្ដាមើលឆោមកាយា
នាងស្រីយក្ខា ឆោមឆើតពេកពន់ ៗ ទេព្ដាចាប់ចិត្តគយគន់
ល្អបមើលមិនធ្អន់ មិនឆ្អែតចិត្តឡើយ ៗ សម្ងំឃើញមើល
មកហើយ គេចមុខកន្ទើយ កន្ទុយក្រោកវៃ ៗ សិនបែរមក
ត្រង់ហើយនៃ ញញឹមប្រិមប្រិយ ទៅរកទេវតា ៗ ហើយ
ផាត់ផាយស្បៃរបេញណា បង្ហាញថនា ឲ្យទេព្ដាយល់ ៗ ទេព្ដា
ឃើញហើយសែនខ្វល់ ស្ទើរនឹងផាប់ខ្យល់ ទុលទប់ពុំបានៗ
ចាប់ចិត្តបង់សិទ្ធរម្យបាន ទំទប់ពុំបាន ក្រោកឡើងម៉្ហា ៗ
ដើរទៅឈរនៅក្បែរទ្វារ ហើយឈប់រេក នៅមាត់ទ្វារនៃៗ
នាងនាដសម្ងំពៃត យល់ទេព្ដានៃ ឈរឈប់រេក ៗ បំបាំង
នៅខាងមាត់ទ្វារ ក្រោកឡើងម៉្ហា ដើរទៅតាមហោង ៗ
បានជួបបានជួនសាសង រួមរក្សាអង្គ អស់ចិត្តហើយនៃៗ
ហើយដើរបែកចេញចាំទៃ ទៅដោយខ្លួននៃ ចាំទៃជាម្គង ៗ

ពីរបីថ្ងៃបានជួបម្តង លួចលាក់ឈ្មោះហោង រៀងរាបទៅណា ៗ

មានកាលយប់មួយទេព្តា ទៅរួមរាំស្នា នឹងនាងសម្ទី ៗ ជួន

ផាឥសូរមកខ្ទី ឃើញផ្ទូឈ្មោះនៃ ក្រៀវក្រាបពេកពន់ ៗ

បែរបទពំនោលវិញណា កាលព្រះអាចារ្យ ទៅ

ដល់ស្តេចទតយន់យល់ ៗ ទេព្តាមករួមមណ្ឌល ទើបព្រះ

ទស្យពល បន្ទុលនៃអគ្គទេវតា ៗ ក្តួតទៅក្រាបគ្រវាឡណា

ហើយទ្រង់ត្រាស់ថា មេហោរដកទង់សម្ទី ៗ ហាង់នេះហៅ

ពេញក្បដប្តី មេហោរអប្រើយ ចង្រៃពេកពន់ណាស់ណា ៗ

ណ្ហើយចុះហាង់កុំសង្កា នៅទីងអញណា អញលែងក្បាលហាង

ហើយនៃ ៗ ឲ្យហាងទៅនៅក្នុងព្រៃ ជាយក្ខិនី លុះដល់ហាង

ក្ស័យនោះណា ៗ សន្ទតត្រូវទឹងខន្ធថា អ្នកមានបុណ្យណា

អស្ចារ្យប្រាកដជាម្តង ៗ ទើបព្រះឥសូរប្រាស់ប្រង ចាប់

នាងទៅហោង ទៅហាលក្នុងព្រៃធំក្រៃ ៗ ក្បែរស្រះ

ប្រាបឈ្នេរដលស័យ ដែលមហាក្សត្រថ្ងៃ ព្រាមហ្មទត្តនៃងទៅ

ប្រពាត ៗ កាលនោះសម្តេចនរនាថ ថាបើហាងឃ្មាត

ពីស្រះនេះទៅពំជា ៗ ប្រាំពីរថ្ងៃឲ្យមរណា បើនៅហន៏ជា
អាយុយឺនយូរគ្រាន់នៅ ៗ ជាស្រេចទើបស្ដេចយាង៏ទៅ កាន់
ទីលំនៅ ឯស្ថានកៃលាសវិញណា ៗ កាលក្រោយព្រះឥស្សូរ
យាង៏ទៅហើយណា រីឯនាង៏នាថសម្ពុទ្ធី ៗ ក្លាយកាយជា
យក្ខិនី ជួរជាតិអប្រិយ អាស្រ័យនៅស្រះនោះណា ៗ
ហើយថ្ងូញរំនួញថ្ងៃង៏ថា គួរស្រណោះណា នាស្ថានកៃលាស
នាយនៃ ៗ កម្មអាក្រក់ក្លាយបេញខ្ញុំ មិនគួរបេត្តិ ត្រូវក្ខជា
មួយទេត្ដា ៗ ទាល់តែខូចខ្លួនអាសារ ព្រាត់ចោលបរិវារ
អាស្នាតែង៏នៅប្រក្រតី ៗ ស្ដេចជិនណាយកាយអប្រិយ យក
មកចោលខ្ញុំ នៅនៃក្នុង៏ព្រៃម្នាក់ឯង៏ ៗ យក្ខិតហើយរឹងបម្បែង៏
ជិតនៅម្នាក់ឯង៏ ផ្ដាប់គេង៏និត្យនៅមានគ្នា ៗ ឥឡូវមកទៅ
កំព្រា ម្នាក់ឯង៏ឯកា ហើយឥតទីស្ថានលំនៅ ៗ គិតគ្រប់
ហើយយកព្រួញទៅ ទីស្ថានលំនៅ នគរហេមវ័ននោះណា
នឹកដល់សម្ដេចជេដ្ឋា វិរុល្ហមេឃណា ជាឧម៉ែះសមអ្នកបង៏ ៗ
គង់សុខស្រណុកជាម្ដង៏ ពុំដឹង៏ឡើយហោង៏ ជាប្អូនកើតទុក្ខ

ណា ៗ ម្ល៉េះអ្នកបងគិតស្មានថា: ជាប្អូននោះណា នៅ
សុខឥតទុក្ខអ្វីឡើយ ៗ តាំងពីថ្ងៃនេះទៅហើយ ម្ចាស់បងប្អូន
អើយ សមប្អូនរងទុក្ខវេទនា ៗ បើមានអ្នកណាជាគ្នា ម្នាក់ឯង
កំព្រា ៗ នៅនាស្រះនេះហើយហោង ៗ ហើយទ្រូញទំនួញ
ជាមួង ទ្រូញទៅស្រីផង នូវនៃហេមវ័ននោះណា ៗ ហើយនឹក
អាណិតខ្លួនថា ធ្លាប់មានទាសា ទាសីបម្រើព្នាះហោង ៗ
ហើយត្រូវអាស្រ័យនៅហោង ម្លប់ឈើជាមួង កាលយប់
កាលថ្ងៃទៅណា ៗ ថ្ងៃងិតល្ងាចមេឃយំគក្រ នឹកប្អូនកនិដ្ឋា
ក៏ចាប់ផ្ដិបងរោះខ្ចី ៗ ស្រុះផ្ទុះសំពៅទៅឆ្ងាយ ទីស្ពានព្រះ
ឥ — សូរនៃកៃលាសនោះណា ៗ យក្ខបូលគាល់អង្គព្រះ
មហា ក្រូញក្រាបនៅនា ត្រំហាំនហាស្ដីស្ងៀមនៅ ៗ

x

x x

ចប់ខ្សែ ១ ដោយសង្ខេបតែប៉ុណ្ណោះ

សូមរង់ចាំអានខ្សែ ២ ទៀត ពីព្រោះហើយកំសត់ផង ៗ

# សៀវភៅដែលផ្សាយចេញពីបណ្ណាគារសុជីវិត

នារីកំសត់ ទី ១-២-៣ (ចប់) អ៊ឹង-ឡាយ

មហាឃាតកម្ម ---------------- "

ស្នេហាដូចទឹក ---------------- "

សូរកាំភ្លើងក្រោយសម្រេនម៉ុនតាល័ន — គឹម-សែត

នារីពេត្រី ---------------------- "

ទស្សនាវដ្ដីជីវិត និពន្ធបម្រុះ

ព្រះលក្ខណ៍ស៊ិន្នវង្ស ទី ១-២-៣ សុជីវិត

# សៀវភៅដែលចេញបន្តពីរោងពុម្ពទៀត

សៀវភៅព្រះលក្ខណ៍ស៊ិន្នវង្ស ទី ៤-៥ សុជីវិត

ព្រមមិនឈ្មោះព្រេង, ម៉ាក់ចឺង, អនាគតវង្ស, ពោធិវង្ស, កួន-ម៉ាល័យ, សុគុណាថាន, ល្បើកដុប, តាដក់, អង្គុបកណ្ដារ សុកិណ្ណាវង្ស-ឃុកិណ្ណាវង្ស, អេណារ-នាងបុស្សបា-ៗ ព្រះជិនវង្សៗ ផាវរឿង — បំពេញករណីយកិច្ចមិនភ្លេចស្នេហា — លោកជីវិត

នេះសុទ្ធតែរឿងព្រេងបុរាណគតិ

រោងពុម្ពបុញ្ញាចារ្យ

តម្លៃ ១២៛០០